មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ ទៀន ម៉ៅ ភេទស្រី អាយុ៦៨ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ កងចល័ត**

**សព្វថ្ងៃរស់នៅភូមិកណ្តាលលើ ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២**

**សម្ភាសន៍ដោយៈ សុខ វណ្ណៈ**

**០១:០៩:៥៥**

**៣៣ទំព័រ..**

វណ្ណៈ : អញ្ចឹងថ្ងៃហ្នឹង ថ្ងៃទី១៨ ខែ៥ ឆ្នាំ២០១២ ខ្ញុំឈ្មោះសុខវណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាណាអ៊ំណាបាទ! ហើយខ្ញុំមកដល់ភូមិ-ឃុំ អ៊ំហ្នឹងចង់សម្ភាសទាក់ទងនឹងរឿងរ៉ាវប្រវត្តិសាស្ត្រជាពិសេសទាំងទងនឹងតំបន់នៅអន្លង់វែងក្រោយ៧៩ហ្នឹង ថាយើងជួបបញ្ហាអីខ្លះ ក្រោយមកយើងធ្វើសមាហរណកម្មអីអញ្ចឹងណា ហើយខាងមជ្ឈមណ្ឌលខ្ញុំហ្នឹងគឺត្រូវបានក្រសួងទេសចរណ៍ហ្នឹងអឺឲ្យចុះមកសម្ភាសប្រជាជន ហើយចុះមកគឺចង់បានដឹងរឿងរ៉ាវនៅអន្លង់វែងហ្នឹងដើម្បីយកសរសេរសៀវភៅមគ្គុទេសក៍អន្លង់វែង មគ្គុទេសក៍ទេសចរណ៍ អន្លង់វែងដើម្បីឲ្យស្រុកអន្លង់វែងហ្នឹងអាចប្រើថាមានមុខមាត់ថ្មីទៀត គេស្គាល់ស្រុកអន្លង់វែង អីអញ្ចឹងណាបាទ! ហើយបទសម្ភាសជាមួយអ៊ំជាមួយខ្ញុំហ្នឹងគឺថា អ៊ំអនុញ្ញាតឲ្យសរសេរយកទៅសរសេរអីអត់ឲ្យក្មេងជំនាន់ក្រោយបានដឹងបានឮអត់អ៊ំ អ៊ំមិនថាអីទេ?

ម៉ៅ : ទេ មិនថាអី ប៉ុនថាខ្ញុំវាមិនសូវដឹងអីដែរហ្នឹងណា ។

វណ្ណៈ : បាទ! អត់អីទេកន្លែងណាដឹងក៏ដឹងទៅ កន្លែងណាមិនដឹងក៏យើងក៏អត់អីដែរណាអ៊ំណា ។

ម៉ៅ : ចា៎!

វណ្ណៈ : ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ំ អ៊ំឈ្មោះអីទៅ?

ម៉ៅ : ខ្ញុំឈ្មោះ ទៀន ម៉ៅ ។

វណ្ណៈ : បាទ?

ម៉ៅ : ទៀន ។

វណ្ណៈ : ទៀន ម៉ៅ?

ម៉ៅ : ចា៎! ទៀន ម៉ៅ ។

វណ្ណៈ : អ៊ំអាយុប៉ុន្មានហើយ?

ម៉ៅ : ចា៎ ៦៤ ។

វណ្ណៈ : ចុះប្ដីអ៊ំឈ្មោះអី?

ម៉ៅ : ឈ្មោះ យៀវ សាត ។

វណ្ណៈ : ឈ្មោះ?

ម៉ៅ : យៀវ សាត ។

វណ្ណៈ : យៀវ?

ម៉ៅ : ចា៎!

វណ្ណៈ : យៀវ សាត?

ម៉ៅ : យៀវ សាត «យ» «ៀ» និង «វ» ។

វណ្ណៈ : សាត?

ម៉ៅ : ចា៎!

វណ្ណៈ : គាត់អាយុប៉ុន្មានហើយ?

ម៉ៅ : ហ៊ឹម គាត់ខូចតាំងពីអាយ៦៤ ។

វណ្ណៈ : ស្លាប់ហើយ?

ម៉ៅ : ចា៎! ស្លាប់២ឆ្នាំហើយ ។

វណ្ណៈ : បាទ! អ៊ំមានកូនប៉ុន្មានកូនអ៊ំទាំងអស់?

ម៉ៅ : ខ្ញុំកូន៣នាក់ ។

វណ្ណៈ : តែ៣នាក់ហ្នឹងទេ?

ម៉ៅ : ចា៎!

វណ្ណៈ : ស្រីប៉ុន្មាន?

ម៉ៅ : ស្រី២ ប្រុស១ ។

វណ្ណៈ : បាទ! ឪពុកអ៊ំឈ្មោះអីដែរ?

ម៉ៅ : ឪពុកខ្ញុំឈ្មោះ ហួត ។

វណ្ណៈ : ត្រកូលគាត់ស្គាល់ទេ?

ម៉ៅ : ត្រកូលអត់ស្គាល់ផង ។

វណ្ណៈ : ស្គាល់តែហួត?

ម៉ៅ : ចា៎! ទឹម ហួត ។

វណ្ណៈ : ទឹម?

ម៉ៅ : ខឹម ហួត ។

វណ្ណៈ : ម្ដាយ?

ម៉ៅ : ម្ដាយឈ្មោះ ហាង ។

វណ្ណៈ : អត់ស្គាល់ត្រកូលគាត់ទេ?

ម៉ៅ : អត់ ទៀង ហាង អូ! មិនមែនទេ ដឹងស្អីទេ អត់ស្គាល់សោះ ។

វណ្ណៈ : ឈ្មោះ ហាង អញ្ចឹង?

ម៉ៅ : ចា៎!

វណ្ណៈ : ចុះអ៊ឹមានបងប្អូនទាំងអស់ប៉ុន្មាននាក់ពីដើមមក?

ម៉ៅ : ខ្ញុំបងប្អូនច្រើនណាស់ខ្ញុំនោះ ១៣ណោះ ។

វណ្ណៈ : យី! ច្រើនណាស់ណ៎?

ម៉ៅ : ចា៎!

វណ្ណៈ : ១៣នាក់ សព្វថ្ងៃនៅសល់ប៉ុន្មាននាក់អ៊ឹ?

ម៉ៅ : នៅសល់៨ ។

វណ្ណៈ : ៨នាក់ហ្នឹងនៅរស់នៅអន្លង់វែងដែរ ឬរស់នៅស្រុកកំណើត?

ម៉ៅ : រស់នៅស្រុកកំណើត ។

វណ្ណៈ : បាទ! ចុះអ៊ឹអ៊ឺស្រុកកំណើតអ៊ឹនៅណាវិញ?

ម៉ៅ : ខ្ញុំនៅកំពត ។

វណ្ណៈ : កំពតហ្នឹង នៅភូមិអីអ៊ឹ?

ម៉ៅ : នៅភូមិត្របៀត ។

វណ្ណៈ : ភូមិអីគេ?

ម៉ៅ : ភូមិត្របៀត ។

វណ្ណៈ : ភូមិត្របៀត?

ម៉ៅ : ចា៎! ស្រុកអង្គរជ័យ ឃុំសំឡាញ ស្រុកអង្គរជ័យ ។

វណ្ណៈ : ភូមិត្របៀត ឃុំ?

ម៉ៅ : សំឡាញ ។

វណ្ណៈ : សំឡាញ ។

ម៉ៅ : ស្រុកអង្គរជ័យ ។

វណ្ណៈ : ខេត្តកំពតមែនទេ?

ម៉ៅ : ចា៎! កាលមុនខេត្តតាកែវ តែឥឡូវកាត់មកកំពតណា ។

វណ្ណៈ : បាទ! ចុះឥឡូវអ៊ំនៅភូមិអី ឥឡូវ?

ម៉ៅ : សព្វថ្ងៃនេះ?

វណ្ណៈ : បាទ!

ម៉ៅ : នៅកណ្តាលលើ ។

វណ្ណៈ : នៅកណ្តាលលើ?

ម៉ៅ : ចា៎!

វណ្ណៈ : ឃុំ?

ម៉ៅ : ឃុំអន្លង់វែង ។

វណ្ណៈ : ស្រុក?

ម៉ៅ : ស្រុកអន្លង់វែង ។

វណ្ណៈ : ខេត្ត?

ម៉ៅ : ខេត្តនេះ ខេត្តឧត្តរមានជ័យណា ។

វណ្ណៈ : កាលៗអ៊ំនៅតូចបានរៀនសូត្រអត់អ៊ំ?

ម៉ៅ : អត់ ។

វណ្ណៈ : អត់បានរៀនសូត្រទេ?

ម៉ៅ : ចា៎! អត់បានរៀន ។

វណ្ណៈ : មូលហេតុអីបានអ៊ំអត់បានរៀនអ៊ំ?

ម៉ៅ : ហើយចុះស្រុកយើងនៅជនបទឆ្ងាយ អត់មានសាលារៀន ទើបឥឡូវមានបង្កើតសាលារៀន ។

វណ្ណៈ : បាទ! អ៊ំថាឆ្ងាយអត់មានសាលារៀន មិនមែនដោយសារសង្គ្រាមដោយសារអី?

ម៉ៅ : ទេ អត់ទេ! ឆ្ងាយដល់ហើយខ្ញុំការហើយ(០០:០៥:៤៥) ឆ្ងាយពីសាលារៀនមែនណា ស្រុកខ្ញុំ អត់មានសាលារៀនទេ ហើយម្យ៉ាងបងប្អូនខ្ញុំច្រើនផង ម៉ែឪខ្ញុំក៏ ។

វណ្ណៈ : អញ្ចឹងឲ្យរៀនតែប្រុសៗទេ?

ម៉ៅ : ប្រុសៗបានរៀន អត់តែកូនស្រី អត់បានរៀន ។

វណ្ណៈ : អញ្ចឹងអ៊ំ មិញ១៣នាក់បងប្អូនបង្កើត១៣នាក់តែម្តង?

ម៉ៅ : ១៣នាក់ បងប្អូនបង្កើត ។

វណ្ណៈ : ប្រុសប៉ុន្មាន ១៣នាក់ហ្នឹង?

ម៉ៅ : ប្រុស៧ ។

វណ្ណៈ : អញ្ចឹងបងប្អូនអ៊ំមានចូលចលនាតស៊ូ ឬក៏អីដែរកាលហ្នឹងដូចថាចូលព្រៃម៉ាគី ចូលអី?

ម៉ៅ : មាន ។

វណ្ណៈ : មានចូលបដិវត្តន៍ប៉ុន្មាននាក់កាលហ្នឹង?

ម៉ៅ : ៣ ។

វណ្ណៈ : ៣នាក់?

ម៉ៅ : ចា៎! ៣ទាំងខ្ញុំហ្នឹងណា ប៉ុន២នោះស្លាប់អស់ហើយ ។

វណ្ណៈ : អ៊ំចូលបដិវត្តន៍ អ៊ំចូលនៅឆ្នាំណាដែរ?

ម៉ៅ : ចូល ខ្ញុំមិនចូលនេះទេ ខ្ញុំចូលឆ្នាំ៧៥ហើយ ទាល់ប្ដីខ្ញុំទេបានចូលតាំងពូយូរមកពេលឆ្នាំ៧៥ នោះដល់ភ្នំពេញគាត់យកខ្ញុំតាម ។

វណ្ណៈ : អញ្ចឹង អ៊ំការតាំងពីឆ្នាំណា?

ម៉ៅ : ខ្ញុំការតាំងពី៦៣ ៦៣-៦៤បានខ្ញុំមាន ។ ប៉ុនខ្ញុំកូនឡើង៥នាក់នោះ តែកូនវាបែកអស់ទៅ វាស្លាប់អស់ទៅ បានខ្ញុំដាក់សព្វថ្ងៃនៅរស់តែ៣ងហ្នឹង ក៏ដាក់តែ៣ ។

វណ្ណៈ : បាទ!

ម៉ៅ : ស្លាប់២ ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ២បង១គេ ។

វណ្ណៈ : បាទ!

ម៉ៅ : កូន៥ ។

វណ្ណៈ : ប្ដីអ៊ំឈ្មោះ សាត ហ្នឹងគាត់ចូលបដិវត្តន៍តាំងពីជំនាន់សម្ដេចឪប្រកាស?

ម៉ៅ : ហ្នឹងហើយ សម្ដេចឪប្រកាស ប៉ុនដល់ពេល ដល់៧២ហើយបានគាត់ចូល ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ចា៎! សម្ដេចប្រកាសហ្នឹងអត់ទាន់ទេ ដូចថាធ្វើការក្នុងភូមិ ក្នុងឃុំអញ្ចឹងណា ហើយកាលសម្ដេចឪប្រកាសហ្នឹងចេះតែចង់ហើយប៉ុនដល់មានកូនអញ្ចឹងទៅ ដល់អាពេលកប៉ាល់ហោះទម្លាក់អាបេ៥២ទម្លាក់មក បានគាត់មកនៅកន្លែងស្រុក ។

វណ្ណៈ : យន្តហោះទម្លាក់ស្រុកអ៊ំហ្នឹង តើពេលដែលទម្លាក់ហ្នឹងតើមានបញ្ហាគ្រោះថ្នាក់អីដែរ ឬផ្ទះសម្បែងប្រជាជនស្លាប់អីមានទេ?

ម៉ៅ : មាន ។

វណ្ណៈ : អ៊ំឃើញផ្ទាល់ភ្នែក ឬក៏យ៉ាងម៉េច?

ម៉ៅ : អាហ្នឹង ដូចកាលនោះវាទម្លាក់អញ្ចឹង អាបេ៥២ទម្លាក់ យើងអត់សូវហ៊ាននៅក្នុងភូមិអញ្ចឹង យើងមកនៅតាមព្រៃណា ទម្លាក់ហ្នឹង១គ្រួសារនោះ៤នាក់ទាំងអស់ អត់មានកាយទល់សព្វថ្ងៃ មិនដឹងកាយយ៉ាងម៉េចបើបេ៥២ហ្នឹងទម្លាក់ទៅ ដល់វាខ្ទាតទៅលើរងហ្នឹង លុបឡើងអស់រលីង ។

វណ្ណៈ : គ្រួសារក្នុងភូមិជាមួយគ្នាហ្នឹង?

ម៉ៅ : ចា៎! នៅភូមិជាមួយគ្នា ។

វណ្ណៈ : ស្គាល់ឈ្មោះគ្រួសារហ្នឹងទេ ដែលទម្លាក់គ្រាប់បែក ទម្លាក់ត្រូវ?

ម៉ៅ : ឈ្មោះអីទេភ្លេចបាត់ទៅហើយ មើល៣០ឆ្នាំជាងហើយ អ៊ំហឿន អ៊ំស្រីណាឈ្មោះហឿន ប្តីនោះអ៊ំហាក់ ប្តីគាត់ ហើយកូន២ កូនមួយនោះទើបកូនង៉ា មិនទាន់មានមិនទាន់ដាក់ឈ្មោះផង ។

វណ្ណៈ : បាទ! អញ្ចឹងឆ្នាំណាដែលទម្លាក់ត្រូវហ្នឹង?

ម៉ៅ : ឆ្នាំ៧២ ។

វណ្ណៈ : អញ្ចឹងមានស្លាប់មនុស្សដែរ កាលហ្នឹង?

ម៉ៅ : ចា៎! ត្រូវតែ១គ្រួសារហ្នឹង ។

វណ្ណៈ : បាទ! ហើយអ៊ំដូចថានៅក្នុងភូមិអ៊ំហ្នឹង កាលហ្នឹងដូចថាជំនាន់ដូចថារដ្ឋប្រហារហើយ យើងចូលបដិវត្តន៍ច្រើនគ្នាដែរកាលហ្នឹង?

ម៉ៅ : មានច្រើនដែរហ្នឹង ។

វណ្ណៈ : ច្រើនដែរ ។ អញ្ចឹងអ៊ំចូលតាមប្តីដែរ ឬក៏យ៉ាងម៉េច?

ម៉ៅ : អត់ទេ ខ្ញុំអត់បានចូលទេ ខ្ញុំនៅរកស៊ីចិញ្ចឹមកូនដល់ឆ្នាំ៧៥រំដោះឆ្នាំ៧៥ បែកហ្នឹងបានយកខ្ញុំតាម ។

វណ្ណៈ : បាទ! អញ្ចឹងដល់ពេលឆ្នាំបែក៧៥ហ្នឹង អ៊ំបានមកនៅជាមួយគាត់នៅណា នៅភ្នំពេញគាត់ឡើងមកភ្នំពេញអញ្ចឹង?

ម៉ៅ : ចា៎! នៅភ្នំពេញ នៅកំពង់សោម ។

វណ្ណៈ : អូ! ទៅខាងកំពង់សោមវិញ?

ម៉ៅ : ចា៎! កំពង់សោម ។

វណ្ណៈ : ប្តីអ៊ំកាលហ្នឹងយោធា?

ម៉ៅ : ចា៎!

វណ្ណៈ : គាត់មានឋានៈធំដែលកាលហ្នឹង ដែលបែក៧៥ហើយ?

ម៉ៅ : នៅ៧៥គាត់កងអនុសេនាតូច ។

វណ្ណៈ : ប្តីអ៊ំអនុសេនាតូច?

ម៉ៅ : ចា៎!

វណ្ណៈ : ពេលឆ្នាំ៧៥មក អ៊ំមានកូនប៉ុន្មាននាក់ហើយ?

ម៉ៅ : ៧៥ កូន៣ ។

វណ្ណៈ : កូន៣នាក់? ១

ម៉ៅ : ចា៎!

វណ្ណៈ : អ៊ំទៅនៅកំពង់សោមហ្នឹង អ៊ំនៅជាមួយទ័ពឬគេបែងចែកយ៉ាងម៉េចទៀត?

ម៉ៅ : អត់ទេ នៅជាមួយអ្នកនេះ អ្នកមានគ្រួសារហ្នឹងនៅតាមសហករណ៍ ។

វណ្ណៈ : នៅតាមសហករណ៍?

ម៉ៅ : សហករណ៍តែគ្នាឯងហ្នឹង ។

វណ្ណៈ : បាទ!

ម៉ៅ : ស្រីៗទាំងអស់គ្នា អត់មានមកតាមគ្រួសារទេ គ្រួសារនៅផ្សេង ។

វណ្ណៈ : បាទ! អញ្ចឹងប្តីអ៊ំនៅទ័ពទៅ អ៊ំនៅតាមសហករណ៍?

ម៉ៅ : ចា៎!

វណ្ណៈ : កំពង់សោមហ្នឹង អ៊ំទៅឆ្នាំ៧៥ អ៊ំចេញទៅតែម្តង?

ម៉ៅ : ឆ្នាំ៧៥-៧៦ហ្នឹងមិនបែក ។

វណ្ណៈ : បាទ! ៧៥ខ្មែរក្រហមបានកាន់កាប់ហើយណាកាន់កាប់ហើយ ឈ្នះ លន់ នល់ ហើយ លន់ នល់ ចាញ់មិនអញ្ចឹងអ៊ំណា?

ម៉ៅ : ចា៎!

វណ្ណៈ : ពេលដែលខ្មែរក្រហមចូលដល់ តាមភូមិហើយហ្នឹងអ៊ំបានទៅជាមួយគ្រួសារអ៊ំហើយ?

ម៉ៅ : ចា៎!

វណ្ណៈ : អញ្ចឹងកាលហ្នឹងគេឲ្យទៅដែរ ប្តីប្រពន្ធអីគេឲ្យយើងទៅអញ្ចឹងដែរ គេអត់ហាមឃាត់ទេ?

ម៉ៅ : ចា៎! អ្នកមានប្តីមានប្រពន្ធគេឲ្យយកតាម ឲ្យទៅយកមកពីស្រុកពីភូមិណា ពីមុននៅតាម សហករណ៍តាមផ្សេង ដល់៧៥បានគេឲ្យទៅតាម ។

វណ្ណៈ : អញ្ចឹងដូចជាកាលហ្នឹង ពេលទៅដល់កំពង់សោមគេឲ្យអ៊ំទៅធ្វើអីវិញ?

ម៉ៅ : អត់មានធ្វើអីផង ធ្វើស្រែៗ (០០:១២:៤៧) ។

វណ្ណៈ : អ៊ំនៅក្នុងក្រុងតែម្ដង ឬក៏នៅខាង(០០:១២:៥០)?

ម៉ៅ : នៅអត់ដល់ក្រុងទេ ខ្ញុំនៅខាងភូមិថ្មី។

វណ្ណៈ : ភូមិថ្មី?

ម៉ៅ : ចា៎! នៅភូមិថ្មី ទៅអត់មានធ្វើអីទេ ធ្វើស្រែពីណាទៅធ្វើស្រែតែម្ដង។

វណ្ណៈ : ភូមិថ្មី?

ម៉ៅ : ភូមិថ្មី។

វណ្ណៈ : ឃុំ?

ម៉ៅ : អត់ដឹងឃុំអីសោះកាលហ្នឹង។

វណ្ណៈ : ស្រុក? អត់ដឹងស្រុកអី?

ម៉ៅ : អត់ដឹង។

វណ្ណៈ : ហើយម៉េចដឹងថាកំពង់សោម?

ម៉ៅ : ចា៎! ដឹងថាកំពង់សោម បើគាត់យកទៅកំពង់សោម។ កាលហ្នឹង គេមានដាក់ជាស្រុកអី ជាឃុំអីផង ប៉ុនដឹងថាភូមិថ្មី ខ្ញុំទៅនៅភូមិថ្មីហ្នឹងតែម្ដង។

វណ្ណៈ : បាទ! អញ្ចឹងកាលអ៊ំនៅជំនាន់ខ្មែរក្រហម សម័យតស៊ូឆ្នាំចិតជាងអីហ្នឹង នៅខាងកំពតហ្នឹង គេហៅតំបន់ប៉ុន្មាន? ភូមិភាគអីកាលហ្នឹង?

ម៉ៅ : គេហៅតំបន់១៣ អាហ្នឹងហៅតំបន់ អាតំបន់តែម្ដងហៅតំបន់១៣ ប៉ុនបើស្រុក ស្រុក ១០៧។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ចា៎! អាហ្នឹងគេហៅស្រុក១០៧។

វណ្ណៈ : អញ្ចឹង ខាងស្រុកអង្គរជ័យគេហៅស្រុក១០៧ ជំនាន់ខ្មែរក្រហមណា?

ម៉ៅ : ចា៎ៗ! ហ្នឹងហើយ។ ១០៦-១០៧ហ្នឹងហើយ។

វណ្ណៈ : ចុះ១០៦នៅខាងណាវិញ?

ម៉ៅ : ១០៦នៅក្រោមខ្ញុំទៀត ហ៎! មកលើអញ្ចេះ១០៦ អាទៅក្រោមទៀត១០៨-១០៩ គេហៅ១០៨-១០៩អញ្ចឹងទៅណា។

វណ្ណៈ : បាទ! ១០០៩ស្រុកអីគេ?

ម៉ៅ : ស្រុកគិរីវង់។

វណ្ណៈ : ចុះ១០៨?

ម៉ៅ : ១០៨ស្រុកអីអញ្ចេះមើល៎ កាលហ្នឹងគេហៅស្រុកអីគេទេ ស្រុកទ្រាំងៗខេត្តតាកែវ

ណា ។

វណ្ណៈ : ចុះ១០៦?

ម៉ៅ : ១០៦ស្រុកត្រាំកក់ ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ចាំ!

វណ្ណៈ : ចុះមានស្រុក១០៥ទេកាលហ្នឹង?

ម៉ៅ : អូ៎! ១០៥ត្រាំកក់ បើ១០៦នៅម្តុំខាងណាអញ្ចេះ ។

វណ្ណៈ : គិរីវង់?

ម៉ៅ : អត់ទេ គិរីវង់១០៩ ។

វណ្ណៈ : ក្រោយវិញ?

ម៉ៅ : ចាំ!

វណ្ណៈ : តែអ៊ីឥឡូវនិយាយបកទៅវិញ ពេលអ៊ីជម្លៀសទៅកំពង់សោម អញ្ចឹងអ៊ីត្រូវបែកចេញពីគ្រួសារបងប្អូនហើយមែនទេ?

ម៉ៅ : ចាំ!

វណ្ណៈ : ឪពុកម្តាយអ៊ីបែកចេញហើយ?

ម៉ៅ : ចាំ!

វណ្ណៈ : ទៅតាមប្តី?

ម៉ៅ : ចាំ!

វណ្ណៈ : អ៊ីប្តីអ៊ីកាលហ្នឹង គាត់នៅខាងយោធាជើងទឹក ឬក៏ជើងគោក?

ម៉ៅ : នៅនឹងជើងទឹកហ្នឹង គាត់នៅកន្លែងកម្មករជួសជុលណា ។

វណ្ណៈ : អញ្ចឹងនៅខាងនោះមានតាមុត អ្នកគ្រប់គ្រង ប្រធានកងពល?

ម៉ៅ : ចាំ! ប្រធានមានតែ តាមុត ណាគាត់គ្រប់គ្រង ។

វណ្ណៈ : អ៊ីស្គាល់តាមុតទេអញ្ចឹង?

ម៉ៅ : ស្គាល់ ។

វណ្ណៈ : ស្គាល់ដែរ?

ម៉ៅ : បើគាត់ប្រធាន ស្គាល់ ។

វណ្ណៈ : ចុះអ៊ីក្រែងនៅតាមសហករណ៍ ម៉េចទៅស្គាល់?

ម៉ៅ : សហករន៍ក៏គាត់ក្តោបក្តាប់នៅលើអ៊ីមុតដែរ ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ចា៎!

វណ្ណៈ : អញ្ចឹងតាមុត គាត់ក្តោបក្តាប់ទាំងខាងទាហានផង ទាំងខាងសហករណ៍នៅខាងកំពង់សោមផង?

ម៉ៅ : ចុះបើសហករណ៍នៅហ្នឹង គាត់ក្តោបក្តាប់ទាំងអស់ នៅលើអ៊ំមុតទាំងអស់ ។

វណ្ណៈ : បាទ! ចុះកាលហ្នឹងអ៊ំរស់នៅតាមសហករណ៍ហ្នឹង តើអ៊ំកន្លែងដែលអ៊ំរស់នៅជួបការលំបាកដែរ ឬក៏មិនអី មិនពិបាកទេ?

ម៉ៅ : លំបាកដែរ ធ្វើស្រែ (០០:១៦:៣៦) ។

វណ្ណៈ : ប៉ុន្តែការហូបចុកណា ហូបចុកដូច?

ម៉ៅ : ហូបចុកមានទៅណា បបរក៏ប៉ុណ្ណឹងអត់ក៏ប៉ុណ្ណឹង បបរគ្មានពេលហូប រកឆ្នាញ់មិនឃើញទេបើយើងសហករណ៍នោះ ។

វណ្ណៈ : អញ្ចឹងលំបាកខ្លះៗដែរ ប៉ុន្តែអត់មានមនុស្សស្លាប់ដោយសារអត់អាហារអត់អីៗទេ?

ម៉ៅ : អត់ទេ ហ្នឹងវាស្លាប់ដោយសារគ្រុនចាញ់អញ្ចឹងណា វាមិនអត់ទេ អ្នកណាឈឺគ្រុនអីអញ្ចឹងណា ។

វណ្ណៈ : ចុះអ៊ំៗនៅហ្នឹងអ៊ំមានដឹងទេ ដូចថាបញ្ហាក្រោយមកនយោបាយមានការផ្លាស់ប្តូរ មានចាប់មេ១ចំនួនហើយចាប់មនុស្សចាប់អី ដឹងទេកាលហ្នឹងជិតនាំ៣ឆ្នាំហ្នឹង?

ម៉ៅ : អត់ ប៉ុនដឹង (០០:១៧:៣១) នៅក្នុងសហករណ៍ ។

វណ្ណៈ : ប៉ុន្តែនៅក្នុងសហករណ៍ហ្នឹង មានគេចាប់មនុស្សចោទថាខ្មាំងថាអី ថាអីអញ្ចឹងមានទេ គេហៅទៅរៀនសូត្រអីមានទេ កាលហ្នឹង?

ម៉ៅ : មានដែរនោះ មេៗគេចាប់ទៅគេ ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ចា៎! ប៉ុនថា គេចាប់នោះគេមិនប្រាប់យើងថាចាប់ទេ គេថាយកទៅរៀនសូត្រមួយរយៈអញ្ចឹងទៅ ។

វណ្ណៈ : បាទ! តែអ៊ំបានដឹងថា?

ម៉ៅ : ខ្ញុំវាមិនដឹងថាគេចាប់អ្នកណាគេយកអ្នកហ្នឹង ប៉ុនគេប្រាប់យើងថាអញ្ចឹងគេមិនឲ្យយើងដឹងមិនឲ្យយើងនោះឡោទេណា ។

វណ្ណៈ : បាទ! ចុះអ៊ំបានដឹងទេ គេប្រាប់មនុស្សមួយចំនួន កន្លែងកងកន្លែងអ៊ំទៅរៀនសូត្រនោះ អ៊ំដឹងទេ ដឹងអ្នកដែលដឹងឈ្មោះគេដែរអត់?

ម៉ៅ : មាន១កន្លំនោះតែម្នាក់ទេ ប្រពន្ធអីខែតែដឹងគាត់ឈ្មោះអីខ្ញុំភ្លេចគាត់ទៅ ដែលប្រពន្ធគាត់ឈ្មោះបងខែ ប៉ុនដល់ប្ដីគាត់ហ្នឹងយកទៅរៀន១រយៈហ្នឹង កាលនោះប្ដីប្រពន្ធគាត់នៅជាមួយជុំជាមួយខ្ញុំដែរហ្នឹង ប៉ុនមិនដឹងភ្លេចឈ្មោះបាត់ហើយ ឈ្មោះអីទេ ។

វណ្ណៈ : ខុបមាអង្គការប្រាប់ទៅរៀនសូត្រអញ្ចឹង ដែលឃើញត្រឡប់មកវិញទេ?

ម៉ៅ : អត់ ។

វណ្ណៈ : អញ្ចឹងដូចអ៊ឹនៅសហករណ៍អញ្ចឹង ប្ដីអ៊ឹនៅយោធាអញ្ចឹងតើប៉ុន្មានថ្ងៃ រយៈប៉ុន្មានទៅអង្គការឲ្យមកជួបគ្នា ជួបអីអញ្ចឹងណាអ៊ឹ?

ម៉ៅ : មិនទៀងទេណា ជួនកាល២ថ្ងៃជួនកាល៣ថ្ងៃ គាត់នៅជិតហ្នឹង ។

វណ្ណៈ : អញ្ចឹងបានន័យថា អាកន្លែងភូមិថ្មីគេហ្នឹង វានៅក្នុងក្រុងកំពង់សោមគេដែរ កាលហ្នឹងនៅជិតដែរ?

ម៉ៅ : ចា៎! នៅជិតដែរ ប្រហែលជីប្រហែលកន្លះគីឡូ ប្រហែលជា២គីឡូ ជិត៣គីឡូ ។

វណ្ណៈ : បាទ! អ៊ឹអាចរៀបរាប់បានទេថាទេសភាពនៅកំពង់សោមនៅជំនាន់៣ឆ្នាំហ្នឹង តើឃើញអ៊ឹមានឃើញអីខ្លះទេ តើនាវាចេញចូលអីមានខ្លះដែរ ឬក៏ម៉េចអ៊ឹ?

ម៉ៅ : ម៉េច?

វណ្ណៈ : តើអ៊ឹជួយរៀបរាប់ដែរ ថាទេសភាពអីខ្លះនៅពេលដែលជំនាន់៣ឆ្នាំ នៅកំពង់សោមហ្នឹងបានឃើញកប៉ាល់ដូចថា កប៉ាល់ទឹក ដូចថាចេញចូលយ៉ាងម៉េចៗដែរ ឃើញទេអ៊ឹ?

ម៉ៅ : អត់ទេ ខ្ញុំឃើញ ខ្ញុំនៅភូមិថ្មីនេះមានឃើញៗ កប៉ាល់ៗវានៅអី ។

វណ្ណៈ : សមុទ្រ?

ម៉ៅ : កំពង់ផែនេះ ចា៎! នៅឯសមុទ្រឯនេះ បើខ្ញុំនៅនោះមិនឃើញនេះផងហ្នឹង ដល់គេប្រុសៗដល់ស្រីៗគេមិនដែលឲ្យដឹងពូអារឿងកំប៉ិកកំប៉ុកអីអញ្ចឹងៗ អត់ទេ ។

វណ្ណៈ : ចុះ ដូចថានៅហ្នឹងប្រធានសហករណ៍ឈ្មោះអី?

ម៉ៅ : ប្រធានសហករណ៍ ឈ្មោះអ៊ឹហៀម ស្រីណាប្រពន្ធគាត់ ប្ដីគាត់ឈ្មោះអ៊ឹ មៀញ ដល់ពេលគេចាប់គាត់អញ្ចឹងមកខ្ញុំពូសួរគេឲ្យគាត់មករៀនសូត្រ ដឹងរៀនឯណាអត់ដឹងងាប់អត់ផង ។

វណ្ណៈ : ចុះប្ដីគាត់ឈ្មោះអី?

ម៉ៅ : អីឈ្មោះអ៊ឹមៀញ ។

វណ្ណៈ : ហើយហៀមហ្នឹង ត្រូវគេឲ្យរៀនសូត្រដែរ?

ម៉ៅ : ដល់ហើយ អត់ទេមុនដំបូងយកប្ដីគាត់មក ដល់យកប្ដីគាត់មកអញ្ចឹង ដល់យូរបានយកអ៊ឹហ្នឹងមកបាត់ដែរ ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ចា៎! មកបាត់ទាំងអស់គ្នាផង នៅសហករណ៍ខ្ញុំហ្នឹងឃើញយក២នាក់នេះឯង ហើយ ។

វណ្ណៈ : ចុះអ៊ីដូចថា ឆ្នាំណាមានដឹងទេមានដឹងឆ្នាំណា គេហៅគាត់ទៅរៀនសូត្រ?

ម៉ៅ : ឆ្នាំណាទេ កាលហ្នឹងដូច៧៧ ៧៧ប៉ុនដល់ខែប៉ុន្មាន ដើមខែចុងខែអត់ដឹងទេ ដឹង៧៧ប៉ុនមិនដឹងខែប៉ុន្មានអីប៉ុន្មានទេ ។

វណ្ណៈ : បាទ! ដល់ពេលយករៀនសូត្រមក ក្រោយមកគេផ្លាស់ៗមេសហករណ៍ថ្មីទៀតទេ?

ម៉ៅ : មេសហករណ៍ថ្មី ដូចអត់ទេ អត់ទេ ។

វណ្ណៈ : អត់ទេអ៊ី?

ម៉ៅ : ចា៎! អត់ទេ ដូចថាអត់មានប្រធានអត់អីអញ្ចឹងណា ដូចថាមានគ្នាឯងនៅហ្នឹងទៅ បេះតែនៅក្តោបក្តាប់គ្នាអញ្ចឹងទៅ ប៉ុនបើឲ្យរៀបចំថ្មីអត់ទាន់មានរៀបទេ មកទល់អាយើងរត់ៗបែកគ្នានេះ ។

វណ្ណៈ : បាទ! ចុះអ៊ីដូចថានៅហ្នឹង គេឲ្យដកស្ទូងចុះក្រៅពីដកស្ទូងគេឲ្យធ្វើអីទៀត?

ម៉ៅ : អត់មានធ្វើអីទេ ក្រៅពីដកស្ទូងនៅផ្ទះដេក ។

វណ្ណៈ : អញ្ចឹងដូចថាប្រធានឃុំ ប្រធានអីស្គាល់ទេ កាលហ្នឹង?

ម៉ៅ : អត់ទេ ១ភូមិហ្នឹងមានតែអ៊ីខ្ញុំទេ គាត់ទទួលខុសត្រូវឃុំ១តែម្តង អត់ដឹងមេឃុំនៅឯណា អីណាផងហ្នឹង ។

វណ្ណៈ : បាទ! ចុះគណៈស្រុកអីស្គាល់ទេ? ចុះមានដឹងថាម៉េចបានដឹងថា តា មុត គ្រប់គ្រងមានដឹងថាម៉េចបាន តា មុត ថាអ៊ីស្គាល់តា មុតៗគ្រប់គ្រងធ្លាប់ទៅហ្នឹង?

ម៉ៅ : ចា៎! គាត់ធ្លាប់ទៅហ្នឹង ដូចថាហៅមីងហ្នឹងទៅរៀនសូត្រអញ្ចឹងទៅ គាត់បង្រៀនអញ្ចេះអញ្ចុះបង្រៀនយើងពីធ្វើស្រែធ្វើភ្លឺនៅអញ្ចឹងនោះ គ្រាន់ដឹងថាតា មុត ហ្នឹងអ្នកគ្រប់គ្រង ។

វណ្ណៈ : អញ្ចឹងគាត់ចុះទៅផ្ទាល់តែម្តង?

ម៉ៅ : គាត់ចុះទៅផ្ទាល់អី តែដល់នេះគាត់មកហៅប្រធានៗដូចថា មានប្រធានដូចថាអ៊ី ហៀមអញ្ចឹងគាត់ហៅប្រធានហ្នឹងឯងមកប្រជុំ ប៉ុនអ៊ីអត់ដែរទេ ។

វណ្ណៈ : អញ្ចឹងអ៊ីម៉េចថាស្គាល់គាត់?

ម៉ៅ : ថីមិនស្គាល់បើគាត់អាសារជិះឡាននេះ ប៉ុនថាគ្រាន់ឲ្យតែប្រជុំអញ្ចឹងខ្ញុំអីអត់ដែលបានទៅប្រជុំណា គ្រាន់ថាជិះឡានគាត់ជិះឡានមកណាថានោះអ៊ី មុត ថីមិនស្គាល់ ។

វណ្ណៈ : ជិះឡានគ្នាប៉ុន្មាននាក់ទៅ?

ម៉ៅ : គ្នាគាត់ជិះឡាន ជួនកាល៣នាក់ ជួនកាល២នាក់ ។

វណ្ណៈ ៖ ឡានអីគេ ស្គាល់ទេ?

ម៉ៅ ៖ អត់ស្គាល់ផង ខ្ញុំមិនដែលស្គាល់ឡានផង ។

វណ្ណៈ ៖ ឡានតូច?

ម៉ៅ ៖ ចាំ! ឡានតូចៗហ្នឹង ។

វណ្ណៈ ៖ មានដឹបូលទេឡានហ្នឹង?

ម៉ៅ ៖ អត់ទេ ជួនកាលគាត់ជិះអាមានដឹបូល ជួនណាអត់ទេ ។

វណ្ណៈ ៖ មើលទៅគាត់មិនមែនមនុស្សកាចទេ ឬកាចដែរ?

ម៉ៅ ៖ មិនដឹងយ៉ាងម៉េចបើមិនដែលនិយាយគ្នាផងហ្នឹង ដល់ឃើញចេះតែថា ថា អ៊ឺ មុត មកក៏អ៊ឺ មុត ហ្នឹងគេ បើថាជួបគាត់ផ្ទាល់អត់ទេ ។

វណ្ណៈ ៖ បាទ! ចុះអ៊ឺដូចថាប្ដីអ៊ឺបានមកលេង បានមកអីដែរ ពេលនៅធ្វើការហ្នឹង?

ម៉ៅ ៖ ចាំ!

វណ្ណៈ ៖ ហើយមនុស្សកាលហ្នឹង នៅកន្លែងភូមិអ៊ឺមានមនុស្សច្រើនទេ សុទ្ធតែប្រពន្ធកម្មារ អ៊ឺដូចថា សុទ្ធតែប្រពន្ធយោធាប្រពន្ធអីទាំងអស់?

ម៉ៅ ៖ ចាំ!

វណ្ណៈ ៖ អត់មានប្រជាជនថ្មី ប្រជាជនអីទេ?

ម៉ៅ ៖ ពួកកម្មករធ្វើរោងចក្រក៏នៅហ្នឹងទាំងអស់គ្នា ។

វណ្ណៈ ៖ បាទ! កម្មកររោងចក្រធ្វើអីខ្លះទៅកម្មករហ្នឹង?

ម៉ៅ ៖ កម្មកររោងចក្រហ្នឹង ដឹងគេធ្វើអីវិញខ្ញុំអត់ដែលបានទៅផង ខ្ញុំនៅកន្លែងខ្ញុំផ្សេង អ្នកគេធ្វើ គេធ្វើផ្សេងខ្ញុំធ្វើ ខ្ញុំអត់មានធ្វើអីទេ ។

វណ្ណៈ ៖ អញ្ចឹងអ៊ឺជិនាន់៣ឆ្នាំហ្នឹង អ៊ឺប្រជាជនធម្មតា ឬក៏ធ្វើយុទ្ធនារីឬក៏ធ្វើស្អីដែរ?

ម៉ៅ ៖ អត់ អត់ទេ ។

វណ្ណៈ ៖ ប្រជាជន?

ម៉ៅ ៖ ចាំ! មិនដែលបានធ្វើយុទ្ធនារីអីទេ បើយើងមានកូននោះ ។

វណ្ណៈ ៖ ប្ដីអ៊ឺទេ ដែលធ្វើយោធាយោអី?

ម៉ៅ ៖ ចាំ!

វណ្ណៈ ៖ អញ្ចឹងអ៊ឺដល់ពេលដូចថាវៀតណាមចូលមកអីអញ្ចឹង នៅឆ្នាំ៧៩ណោ អ៊ឺម៉េចបានអ៊ឺ អ៊ឺរត់ ទៅខាងណាវិញពេលហ្នឹង?

ម៉ៅ ៖ នេះរត់មកស្អីគេ នេះមកបារាំងធ្លាក់មកនេះមកចូលដីថៃ ។

វណ្ណៈ : បាទ!

ម៉ៅ : ហ្នឹងរត់មកពីហ្នឹងមករត់មកគ្មានបាយគ្មានអីទេ ចេញពីកំពង់សោមហ្នឹងមកចេះតែមកដើរទៅ ។

វណ្ណៈ : មកជាមួយប្ដីឬមកម៉េចយ៉ាងម៉េចកាលហ្នឹង?

ម៉ៅ : អត់ទេ រត់បែកគ្នាដល់ហើយទៅបានជួបគ្នា ពេលភ័យអាសន្ននោះអត់បានជួបគ្នាទេ ។

វណ្ណៈ : ចុះរត់ៗ បែកប្ដីដែរ?

ម៉ៅ : ចា៎!

វណ្ណៈ : រួចអ៊ីរត់ជាមួយកូនៗទៅ?

ម៉ៅ : ចា៎! ខ្ញុំរត់ជាមួយកូនៗ ។

វណ្ណៈ : កាលហ្នឹងម៉េចបានអ៊ីមិនគិតថារត់មកខាងអ៊ី ខាងស្រុកកំណើតវិញ?

ម៉ៅ : ទៅស្រុកកំណើតអី បើគេទៅណាទៅហ្នឹងតាមតែគ្នាហ្នឹង ចុះវាមិនដឹងមកស្រុកកំណើតអីតែឯង ដើរគេទៅណាក៏ទៅហ្នឹងទាំងអស់គ្នា រត់ទៅណាក៏ទៅហ្នឹង ឲ្យទាំងទៅទាំងអស់គ្នា ។

វណ្ណៈ : បាទៗ! អ៊ីពេលអ៊ីរត់បែក៧៩ហ្នឹង ម៉េចបានអ៊ីអ៊ីរត់សំដៅទៅព្រំដែនវិញ ហើយក៏មិនរត់មករកស្រុកកំណើតឪពុកម្ដាយ?

ម៉ៅ : ចុះបើគេរត់ទៅណាក៏ទៅហ្នឹងជាមួយតែគ្នាហ្នឹងឯងជុំគ្នា ។

វណ្ណៈ : អញ្ចឹងកាលហ្នឹង មូលហេតុអីយើងភ័យខ្លាចយួនឬក៏ភ័យខ្លាចយ៉ាងម៉េច?

ម៉ៅ : វាមិនដឹងយ៉ាងម៉េចគេថាយួនៗ រត់ភ័យចេះតែខ្លាចទៅៗ ទៅទាំងអស់គ្នានឹងគេនឹងឯងតែម្ដង ។

វណ្ណៈ : ចុះអ៊ីរត់តាមផ្លូវជួបផលលំបាកយ៉ាងម៉េច ឈឺ ចាញ់ ស្លាប់អត់បាយយ៉ាងម៉េច ខ្ញុំដូចថាឃើញរូបថតវេទនាដែរ រូបថតខ្មែរក្រហមថតបានឃើញដេកស្លាប់តាមផ្លូវ តើអាហ្នឹងវាមានអញ្ចឹងមែន ឬមួយយ៉ាងម៉េច?

ម៉ៅ : មានដូចថាអញ្ចឹងទៅ ខាងណាគ្នាឈឺរត់មកតាមផ្លូវអញ្ចឹងឈឺទៅក៏មានថ្នាំសង្កូវស្លាប់មែនណា ស្លាប់តាមផ្លូវអញ្ចឹងទៅហើយអាអ្នកអត់ស្លាប់ក៏ចេះតែទៅទៀតអញ្ចឹងទៅ ។

វណ្ណៈ : ចុះអ៊ី ចុះម៉េចកូនអ៊ីចេះតែរស់បានជាមួយអ៊ីរហូតបានអញ្ចឹងទៅ?

ម៉ៅ : ចុះបើកូនខ្ញុំនៅតូចៗ វាតាមខ្ញុំរហូត ។

វណ្ណៈ : ចុះទៅតាមផ្លូវ អ៊ីចេះតែមានចំណីអាហារឲ្យហូបចុកដែរ?

ម៉ៅ : អត់! ចេះដើរលួចដំឡូង ដំឡូងថៃអីអញ្ចឹងទៅមកឲ្យស៊ី ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ចា៎! មានស្បៀង អត់មានស្បៀងហូបទេ ។

វណ្ណៈ : យើងតែយើងដឹបូងវា អ៊ឹៗ ធ្វើម៉េចចេញពីកំពង់សោមទៅ អ៊ឹបានអីជិះទៅ ទៅដល់?

ម៉ៅ : អត់ទេ ចេញដើរហូត ។

វណ្ណៈ : ដើរពីកំពង់សោមមកខាងណាវិញ ដើរមក?

ម៉ៅ : ដើរចេញមកស្អីទេ មកសំឡូតណាមកអីណាទេខ្ញុំ ខ្ញុំមិនដឹងទេរត់តែតាមគ្នា ។

វណ្ណៈ : ប៉ុន្តែយើងត្រូវបកមកតាមផ្លូវភ្នំពេញវិញ ឬក៏បកកាត់?

ម៉ៅ : អត់ទេ កាត់អញ្ចឹងអត់មានមកភ្នំពេញទេ បើមកភ្នំពេញទៅស្រុកបាត់ហើយ អត់មានតាមភ្នំពេញផងហ្នឹង ។

វណ្ណៈ : កាត់តាមផ្លូវណា នៅមានផ្លូវណាកាត់តាមទៀត មានឆ្លងទូកឆ្លងអីអត់?

ម៉ៅ : អត់មានឆ្លងទេ អត់មានឆ្លងទេឆ្លងស្អីគេឆ្លងអាស្ពានយើងកន្លែងទឹកឯណាទេ មិនមានបានឆ្លងទូកទេ ។

វណ្ណៈ : ចុះអ៊ឹគិតមើលនៅកំពង់សោមនោះ វាសមុទ្រនោះព័ទ្ធជុំវិញហើយ អញ្ចឹងយើង?

ម៉ៅ : ពទ្ធ័ជុំវិញយើងបកមកក្រោយយើងមកក្រោយវិញ យើងមកតាមផ្លូវហ្នឹងវិញមក ដល់ហើយទៅផុតអាផ្លូវហ្នឹងមកផុតអាផ្លូវនេះយើងមកលិច ដឹងមកលិចក៏មកណាទេ កាលហ្នឹងគេដឹងផ្លូវគេចេះតែតាមគេទៅ ។

វណ្ណៈ : ហើយចេះតែដើរៗរហូតទៅ?

ម៉ៅ : ចា៎! ដើរៗ ។

វណ្ណៈ : ប៉ុន្មានខែបានដល់ព្រំដែន?

ម៉ៅ : យូរណាស់ ជិត៣ខែនោះ ។

វណ្ណៈ : អ៊ឹទៅដល់សំឡូតទៀត បាត់ដំបងនេះវិញហ្នឹង?

ម៉ៅ : ចា៎! ចេញមកៗដល់សំឡូតមកដល់នេះហើយក៏គេថា ចេះតែនាំគ្នាទៅអញ្ចឹងទៅ នៅមុខគឺរកមិនឃើញ មកផ្ទះតែឯងដល់យើងមានលុយមានកាក់អី អត់ចេះតែដើរទៅ ។

វណ្ណៈ : ចុះយប់ឡើងចេះតែដេញទៅ?

ម៉ៅ : អត់ដែលឃើញផងហ្នឹងណា ។

វណ្ណៈ : អ៊ឹរត់៧៩ហ្នឹងបណ្ដោយហ្នឹង?

ម៉ៅ : ចា៎! រត់៧៩ហ្នឹង ។

វណ្ណៈ : ដើរឆ្ងាយណាពីកំពង់សោមចេញមក ដល់សំឡូតអត់មានឡានជិះ មានជិះឡានខ្លះដែរអត់ទេ?

ម៉ៅ : ទេ អត់មានឡានទេដើរៗរហូត មានឡានណា ។

វណ្ណៈ : ដល់សំឡូត?

ម៉ៅ : ចា៎!

វណ្ណៈ : សំឡូតខាងបាត់ដំបងនេះ?

ម៉ៅ : សំឡូតខាងប៉ៃលិនអី?

វណ្ណៈ : ហ្នឹងហើយប៉ែកសំឡូតប៉ៃលិនហ្នឹង អាហ្នឹងហួសបាត់ដំបងទៀត ចុះដល់ប៉ៃលិនទៀត ហើយទៅណាទៀតអ៊ី?

ម៉ៅ : ដល់ហើយបានមកស្តីគេ មកបារាំងធ្លាក់មកអីណា គ្មានសួរដឹងទេប៉ុនដឹងគេហៅ ថាតាមតែគេទៅ ។

វណ្ណៈ : បារាំងធ្លាក់ទៅខាងភ្នំព្រឹក ម៉ាឡៃណ៎ ។

ម៉ៅ : ហ្នឹងហើយ បើស្តីគេមើលស្តីគេមួយទៀត មកបារាំងធ្លាក់ហើយមកអី បឹងត្រកួន ។

វណ្ណៈ : អ៊ឹមានដឹងទេ ម៉េចបានគេហៅកន្លែងនោះបារាំងធ្លាក់ៗ?

ម៉ៅ : ពុតែគេថា ប៉ុនមិនដឹងយ៉ាងម៉េចពុគេថាបារាំងធ្លាក់ៗ ។

វណ្ណៈ : បាទ! ហើយម៉ាឡៃមានទៅដល់?

ម៉ៅ : អត់! ចូលតែព្រៃហ្នឹង មានដែលបានចូលក្នុងភូមិផងហ្នឹង ដើរតែតាមគ្នាដេកតែក្នុងព្រៃ ។

វណ្ណៈ : អ៊ឹទៅដល់ជំរុំមានគេជួយទេ?

ម៉ៅ : ទៅដល់ជំរុំៗហ្នឹង បានមានបាយមានអីហូប ។

វណ្ណៈ : អញ្ចឹងដល់ជំរុំបានមានបាយហូប?

ម៉ៅ : ចា៎!

វណ្ណៈ : អ៊ឹដល់ជំរុំអីគេ?

ម៉ៅ : ជំរុំអីទេកាលហ្នឹងនោះ ឃើញគេហៅជំរុំអីទេ កាលនោះទៅក៏ឃើញគេជួយបានឲ្យផ្តល់អង្ករផ្តល់អីហូបហ្នឹងហើយ មិនដឹងជំរុំអីពុគេថាគេជួយហើយៗ ។

វណ្ណៈ : ចុះអ៊ឹរត់ប៉ុន្មានខែដែរ ប៉ុន្មានឆ្នាំបានជួបប្តីវិញ?

ម៉ៅ : ទេខ្ញុំមកដល់ព្រំដែននេះជួបគ្នា ។

វណ្ណៈ : ព្រំដែនណា?

ម៉ៅ : ព្រំដែនថៃ ជិតព្រំដែន ។

វណ្ណៈ : ព្រំដែនថៃណា?

ម៉ៅ : ចា៎!

វណ្ណៈ :	បានប៉ុន្មានជួបប្ដីវិញ?

ម៉ៅ :	៣ខែជាងណា បានមកដល់ព្រំដែនហ្នឹងក៏ គាត់មកដល់ព្រំដែនមុនខ្ញុំ ។

វណ្ណៈ :	អញ្ចឹងបែកតែរយៈពេល៣ខែទេបែកហ្នឹង?

ម៉ៅ :	ចា៎!

វណ្ណៈ :	ពេលបានជួបប្ដីពេលហ្នឹង អ៊ីរំភើបចិត្តទេបានរត់ទៅជួបគ្នា?

ម៉ៅ :	មានអី ។

វណ្ណៈ :	បាទ?

ម៉ៅ :	ជួបគ្នាទៅមានបាយ មានអីហូបដល់គេជំនួយទៅបានបាយហូបវិញ មិនដែលរង្គអត់ ។

វណ្ណៈ :	បាទ! ហើយអីក្រោយមកទៀតអ៊ីមកនៅឯណាទៀតទៅ?

ម៉ៅ :	នៅៗៗនេះហ្នឹងឯង នៅដីថៃ ។

វណ្ណៈ :	នៅណា?

ម៉ៅ :	នៅដីថៃ ។

វណ្ណៈ :	ដីថៃនៅខាងណា ភ្នំដងរែកនេះ ក៏នៅណា?

ម៉ៅ :	ហ៎ នៅខាងលិចៗហើយបានមកនេះ ។

វណ្ណៈ :	ថាម៉េចនៅណាវិញ?

ម៉ៅ :	ដឹងហៅស្អីទេ បើខ្ញុំអត់ដឹងផង ។

វណ្ណៈ :	មិនមែននៅខាងម៉ៅឡៃអីទេ?

ម៉ៅ :	ចា៎!

វណ្ណៈ :	ចុះអ៊ីថារត់មកខាងអូរស្មាច់ មកអូរស្មាច់ដែរអត់ទេ?

ម៉ៅ :	ហ្នឹងហើយមកអូរស្មាច់ហ្នឹង ហើយបានមកនៅនេះ នៅតាមព្រំដែនហ្នឹងហើយ ។

វណ្ណៈ :	អ៊ីមកដល់ភ្នំដងរែកឆ្នាំណាអ៊ី?

ម៉ៅ :	ឆ្នាំ៧៩ ចុង៧៩ ទេមើលឆ្នាំណាទេ ។

វណ្ណៈ :	ប្រហែល១ឆ្នាំទេ បានមកដល់ភ្នំដងរែក?

ម៉ៅ :	៨១ ៨០ក៏៨១ទេ ។

វណ្ណៈ :	អញ្ចឹងមកដល់ភ្នំដងរែកហ្នឹង យើងមកក្រោមការគ្រប់គ្រងរបស់ តា ម៉ុក?

ម៉ៅ :	ចា៎!

វណ្ណៈ :	អ៊ីស្គាល់ តា ម៉ុក ទេ?

ម៉ៅ :	ស្គាល់ ។

វណ្ណៈ : ស្គាល់ដែរ ស្គាល់ជិតជិតទេ?

ម៉ៅ : ស្គាល់ឃើញគេគាត់ជិះឡានជិះអី គេថាឡាន តា ម៉ុក នោះ ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ចា៎!

វណ្ណៈ : ចុះមានដែរសុំលុយ សុំអង្ករគាត់ទេ?

ម៉ៅ : ទេ គាត់បើកអង្ករបើកអីឲ្យហូប ។

វណ្ណៈ : ដឹងតែបើកហើយ តែជួនកាលខ្វះហ៊ានសុំលុយគាត់អីដែរណា ។

ម៉ៅ : អត់ទេ ។

វណ្ណៈ : អ៊ឹអត់ហ៊ានទេ?

ម៉ៅ : អត់ទេ ។

វណ្ណៈ : ឆ្នាំ៨១ អ៊ឹមកនៅលើភ្នំឬក៏យ៉ាងម៉េច?

ម៉ៅ : ៨១ ៨២ណោះ ។

វណ្ណៈ : នៅលើភ្នំតែម្តង?

ម៉ៅ : ចា៎! នៅលើភ្នំ ទឹកដីថៃ ។

វណ្ណៈ : នៅលើភ្នំតែនៅលើដីថៃទេ?

ម៉ៅ : ចា៎! ដីថៃ លើភ្នំមានដីយើងណា ដីថៃ ។

វណ្ណៈ : ចុះអ៊ឹ អ៊ឹមានកូនអញ្ចឹង មាននៅសមរភូមិក្រោយទេ?

ម៉ៅ : ចា៎!

វណ្ណៈ : ចុះប្តីអ៊ឹនៅធ្វើទ័ពបន្តទៀតដែរអត់?

ម៉ៅ : អត់ទេ គាត់ពិការ ។

វណ្ណៈ : គាត់ពិការ?

ម៉ៅ : ចា៎!

វណ្ណៈ : ពិការជើងឆ្នាំណា?

ម៉ៅ : ពិការភ្នែក ។

វណ្ណៈ : ត្រូវគ្រាប់?

ម៉ៅ : ចា៎!

វណ្ណៈ : ត្រូវងងឹតទាំង២ ឬក៏ម៉េច?

ម៉ៅ : ងងឹតតែមួយ តែមិនដឹងម៉េច គាត់អត់ដែលធ្វើការតាំងពីគាត់ត្រូវរបួសហ្នឹងមករហូត ។

វណ្ណៈ : គាត់ត្រូវរបួសឆ្នាំណាទៅ?

ម៉ៅ : ឆ្នាំតាំងពី៨១ទេ កាលហ្នឹងគាត់ដកជំឡូងទៅ ដល់ហើយផ្ទុះមីន៨១ ៨២ហើយដកជំឡូង ។

វណ្ណៈ : កាលហ្នឹងយកទៅព្យាបាលនៅណាវិញទៅ?

ម៉ៅ : ព្យាបាលនៅតាម កាលហ្នឹងអឺសុំគេទៅដីថៃ ។

វណ្ណៈ : អ៊ឺអឺឆ្នាំ៨១-៨២ តាម៉ុកគាត់អឺដូចថាបើកអង្ករឲ្យយើងហូប គេបើកប្រជាជនឲ្យហូបអញ្ចឹង អត់ខ្វះខាតទេអឺ?

ម៉ៅ : អត់ខ្វះដែរហ្នឹងណា បានមកគ្រប់ពេលអ្នកណាក៏បានហូប មានអ្នកណាមួយអត់អ្នកណាមួយបាន វាមិនគ្រប់គ្រាន់ ។

វណ្ណៈ : អ៊ឺដូចថាយើងនៅលើភ្នំជួបការលំបាកដែរ ឬក៏មិនសូវពិបាកទេអឺ?

ម៉ៅ : អត់មានពិបាកអី ហូបអង្ករស្រាប់ ។

វណ្ណៈ : បាទ! ប៉ុន្តែអឺមានបានជួយបិត ដូចថាកាលហ្នឹងឆ្នាំណាជួយបិតចម្រូងបិតអី យើងជួយដែរកាលហ្នឹង ប្រជាជនអាចជួយដែរ?

ម៉ៅ : មាន ។

វណ្ណៈ : ប្រជាជននៅក្នុងជំរុំហ្នឹងអាចជួយអី ផ្តល់អីខ្លះដែរ?

ម៉ៅ : ជួយតើជួយគាត់បិតចម្រូងបិតអី ។

វណ្ណៈ : ឆ្នាំណាដែលជួយបិតចម្រូងហ្នឹង?

ម៉ៅ : ឆ្នាំណាទេ ខ្ញុំមិនសូវចាំឆ្នាំទេ ។

វណ្ណៈ : បាទ! ចុះអឺមានដឹងថា អាលើភ្នំហ្នឹងណា ផ្លូវលើភ្នំហ្នឹងតាម៉ុកគាត់ឈូសឆ្នាំណា?

ម៉ៅ : ឆ្នាំណាទេ អត់ចាំឆ្នាំទេ មិនដឹងឈូសកាលណាទេ ខ្ញុំអត់ដឹង ។

វណ្ណៈ : អឺ អញ្ចឹងអឺគិតមើលកាលអ៊ុនតាក់ណា កាលជំនាន់អ៊ុនតាក់អឺដឹងដែរតើ អ៊ុនតាក់ចូលមកអឺដឹងដែរតើអី?

ម៉ៅ : ទេ អ៊ុនតាក់មកនៅនេះហើយតើ មកក្រោមវិញហើយមកពីដីថៃមកវិញហើយ ។

វណ្ណៈ : បាទ! អឺចុះមកក្រោមហើយ?

ម៉ៅ : ហ្នឹងហើយ អ៊ុនតាក់មកនៅក្រោមនេះហើយ ។

វណ្ណៈ : ហើយអឺចុះមកដែរកាលហ្នឹង?

ម៉ៅ : មក ។

វណ្ណៈ : មកនៅភូមិណាមកនៅកន្លែងណា?

ម៉ៅ : មកនៅហ្នឹងតែម្តង ។

វណ្ណៈ : មកនៅកន្លែងហ្នឹងតែម្ដង?

ម៉ៅ : ចា៎!

វណ្ណៈ : ចុះដល់ក្រោយមកឃើញបាញ់ខាងរដ្ឋកម្ពុជា បាញ់ហ្វោងមកឃើញរត់ឡើងភ្នំ១សារទៀតមែនដែរ?

ម៉ៅ : ហ្នឹងរត់ទៅ១សារទៀត ពេលគេបាញ់រត់ឡើងទៅទៀតទៅ។

វណ្ណៈ : កាលឆ្នាំណារត់ឡើងម្ដងទៀត?

ម៉ៅ : មិនដឹងឆ្នាំណាទេ ដឹង៩៣ក៏៩៤កាលនោះ។

វណ្ណៈ : បាទ!

ម៉ៅ : បើមិន៩៣ ៩៤ចា៎! ប៉ុនដឹង៩៣ ក៏៩៤ទេ។

វណ្ណៈ : អញ្ចឹងថាចុះមកថាឆ្នាំ៩០អី ថាចុះមក។ ចុះមកបានប៉ុន្មានឆ្នាំរត់ឡើងលើវិញ?

ម៉ៅ : ហ្នឹងឯង ដល់ពេលគេវ៉ៃគ្នាហ្នឹងហើយរត់ឡើងទៅលើវិញម្ដង។

វណ្ណៈ : អឺកាលនៅលើភ្នំណា អឺកាលហ្នឹងអឺដែលឃើញ ប៉ុល ពត តា នួន ជា តាខៀវ សំផន អីទេ?

ម៉ៅ : អត់។

វណ្ណៈ : ឃើញតែ តា ម៉ុក ទេ?

ម៉ៅ : ចា៎! តា ម៉ុក នោះមិនដែលឃើញជិតផង។

វណ្ណៈ : អញ្ចឹងពេលរត់ឡើងភ្នំវិញអឺ ឆ្នាំណាបានអឺចុះមកហ្នឹងវិញ?

ម៉ៅ : អត់ទេ រត់ទៅបានប្រហែលជា។

វណ្ណៈ : ប៉ុន្មានឆ្នាំ?

ម៉ៅ : ប្រហែលកន្លះខែ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ចា៎! ប្រហែល១ខែចុះមកវិញ មកនៅហ្នឹងវិញ។

វណ្ណៈ : ចុះមកនៅហ្នឹងវិញ?

ម៉ៅ : ចា៎!

វណ្ណៈ : អឺកាលហ្នឹងអឺដឹងអី ដូចថាតាម៉ុកជាមនុស្សយ៉ាងម៉េចដែរ គាត់កាចទេក្រែងគាត់ស្លូត?

ម៉ៅ : ដឹងគាត់កាច គាត់ស្លូតអត់ដែលនៅជាមួយគាត់ផង។

វណ្ណៈ : ទេ នៅក្រោមការគ្រប់គ្រងគាត់ដែរ បើកអង្ករគាត់ហូបនោះ។

ម៉ៅ ៖ បើកតែអ្នកគេទទួលខុសត្រូវនេះ យើងដឹងថាគាត់កាចមិនដឹងគាត់កាចរបៀបម៉េចបើយើងមិនដឹង បើនៅជាមួយគាត់បានដឹងថាគាត់កាចរបៀបម៉េច បើយើងមិនដែលនៅផ្ទាល់ជាមួយគាត់ផង ។

វណ្ណៈ ៖ ចុះអ៊ីកាលហ្នឹងគេបាញ់សម្លាប់គ្រួសារ សុន សេន ណាអ៊ីដឹងទេកាលហ្នឹង អត់ដឹងទេ?

ម៉ៅ ៖ ចា៎! ខ្ញុំមិនដឹងរបៀបយ៉ាងណា ខ្ញុំក៏មិនដឹង ។

វណ្ណៈ ៖ ចុះដល់ពេលក្រោយមកគេចាប់ តា ០៥-០៦ តា សារឿន តាអីអ៊ីដឹងទេ?

ម៉ៅ ៖ ដឹង តែមិនដឹងមូលហេតុអីបានគេចាប់ ។

វណ្ណៈ ៖ យើងប្រជាជនអត់ដឹងទេ?

ម៉ៅ ៖ ចា៎! យើងប្រជាជនយើងអត់ដឹង ។

វណ្ណៈ ៖ គេឲ្យទៅណាទៅហ្នឹងទៅ?

ម៉ៅ ៖ ថាគេឲ្យទៅណាទៅហ្នឹង ។

វណ្ណៈ ៖ ចុះអ៊ីដូចថា កាលហ្នឹងអ៊ីដឹងថាតាម៉ុកគាត់កសាងបានអីខ្លះដែរអ៊ី?

ម៉ៅ ៖ ដឹងតែកសាងហើយ កសាងមន្ទីរពេទ្យ សាលារៀនអីគាត់ហើយ ។

វណ្ណៈ ៖ បាទ!

ម៉ៅ ៖ ហើយ និងផ្លូវ ផ្លូវហ្នឹងគេទើបធ្វើក្រោយគាត់ទេ ។ គាត់កសាងបានមន្ទីរពេទ្យ សាលារៀន ផ្លូវ ស្ពាន ស្ពានអូរជីកហ្នឹង ។

វណ្ណៈ ៖ អីទៀតអ៊ី?

ម៉ៅ ៖ មានប៉ុណ្ណឹង ។

វណ្ណៈ ៖ ទំនប់ទឹក ទំនប់ថ្មីទំនប់អី?

ម៉ៅ ៖ ទំនប់ថ្មីអាហ្នឹងក៏គាត់ដែរ ។

វណ្ណៈ ៖ អញ្ចឹងតាម៉ុកបានកសាងច្រើនដែរ អ៊ី?

ម៉ៅ ៖ កាលហ្នឹងឃើញជាក់ស្តែងដែលគាត់កសាងហ្នឹង ប៉ុណ្ណឹងឯង ។ អាទំនប់ថ្មីនោះបានត្រីបានអី យើងប្រជាជនរស់សព្វថ្ងៃ ។

វណ្ណៈ ៖ បាទ! អ៊ីដល់ពេលខ្មែរក្រហមត្រូវជាមួយរដ្ឋាភិបាលឆ្នាំណាអ៊ីចាំទេ យើងស្រុកយើងបានសន្តិភាពស្រុកយើងលែងវ៉ៃគ្នា? អត់ចាំឆ្នាំទេអ៊ី?

ម៉ៅ ៖ អត់ ។

វណ្ណៈ : ចុះអ៊ំគិតថាអញ្ចេះ កាលរស់នៅជំនាន់ តា ម៉ុក ក្រោយ៧៩ណារស់នៅលើភ្នំអីហ្នឹងណា ហើយបើប្រៀបធៀបមកដល់យើងរស់នៅសម័យឥឡូវនេះ តើអ៊ំគិតថាមួយណារស់នៅស្រួលជាង អ៊ំគិតមើល?

ម៉ៅ : នៅសម័យនោះ យើងមាននៅបានធ្វើស្រែធ្វើភ្នំអី យើងរកស៊ីខ្លួនឯង មានតែតាទេគាត់ចិញ្ចឹមអន្តរ ដល់មកឥឡូវយើងរកខ្លួនឯងមានអី ។

វណ្ណៈ : អ៊ំថានៅដូច តា ម៉ុក ស្រួលជាង ឬក៏រស់នៅដូចឥឡូវនេះស្រួលជាង?

ម៉ៅ : ទេ រស់នៅឥឡូវមានសិទ្ធិសេរីភាពជាង ។

វណ្ណៈ : ឥឡូវមានសិទ្ធសេរីភាពជាង?

ម៉ៅ : ចាំ!

វណ្ណៈ : យើងមានលុយធ្វើផ្ទះ ក៏អត់មានអ្វីរករឿង?

ម៉ៅ : ចាំ!

វណ្ណៈ : តែរស់នៅជាមួយ តា ម៉ុក យើងបានតែ១ហូប កូនចៅអត់បានរៀនសូត្រទេ ក៏បានរៀនដែរ?

ម៉ៅ : មានរៀនខ្លះកាលនោះ ។

វណ្ណៈ : បាទ! តែមិនបានច្រើនទេ?

ម៉ៅ : អត់បានច្រើន ។

វណ្ណៈ : អញ្ចឹងអ៊ំគិតថាមួយណាល្អជាង ប្រៀបធៀប តា ម៉ុក ហើយមកដល់សម័យឥឡូវនេះ?

ម៉ៅ : សម័យឥឡូវគេមានសិទ្ធសេរីភាពច្រើនជាងកាលជំនាន់ តា ម៉ុក ។

វណ្ណៈ : អញ្ចឹងគេល្អជាង?

ម៉ៅ : ចាំ!

វណ្ណៈ : បាទ! អញ្ចឹងខ្ញុំចង់សួរបកទៅអីជំនាន់កាលពីដើមវិញ កាលពីដើមណាគ្រួសារអ៊ំ បងប្អូនអ៊ំកាន់សាសនាអីដែរ?

ម៉ៅ : មិនដឹងកាន់សាសនាអី បើខ្ញុំមិនដែលដឹងបើមានសាសនាតែមួយហ្នឹង ។

វណ្ណៈ : សាសនាអីតែមួយ?

ម៉ៅ : សាសនាព្រះពុទ្ធណា ។

វណ្ណៈ : អញ្ចឹងអ៊ំ រាល់ថ្ងៃកាន់ព្រះពុទ្ធដែរ ឬក៏កាន់សាសនាផ្សេង?

ម៉ៅ : ខ្ញុំកាន់ព្រះពុទ្ធ ។

វណ្ណៈ : តាំងពីដើមមកទៅវត្តទៅវ៉ាទៅ?

ម៉ៅ ៖ មកតែប៉ុណ្ណឹងពីម៉ែពីឪពីយាយតាខ្ញុំ មកប៉ុណ្ណឹងៗអត់ហ៊ាន ។

វណ្ណៈ ៖ អ៊ំគិតថាយើងទៅវត្ត យើងមានបំណងប្រាថ្នាធ្វើអី ទៅវត្តហ្នឹងខបមាថាយើងកាន់បាយសម្ងទៅវត្ត ឬក៏ធ្វើបុណ្យទៅវត្តហ្នឹង អ៊ំគិតថាម៉េចបានអ៊ំនឹកឃើញថាទៅវត្តទៅវ៉ាហ្នឹង?

ម៉ៅ ៖ នឹកឃើញពីម៉ែ ពីឪ ពីយាយពីតាយើងមក ពីដើមឡើយគាត់ចាស់ទុំអញ្ចឹងក៏គាត់ទៅវត្តបានបាយបានសម្ងទៅវត្តអញ្ចឹង ។ បើរបស់យើងឥឡូវពីសម័យយើងឥឡូវនេះក៏នឹកឃើញតែប៉ុណ្ណឹងដូចតែគ្នា ។

វណ្ណៈ ៖ អញ្ចឹងអ៊ំគិតថាធ្វើបុណ្យហ្នឹងអាចប្រាថ្នាជាតិក្រោយ អ៊ំជឿជាក់ថាបានសុខបានសប្បាយអីអញ្ចឹងបានអ៊ំទៅ?

ម៉ៅ ៖ ទេ យើងដុតធូបប្រាថ្នាទៅថាយើងជាតិណាៗទៅកុំឲ្យវេទនាដូចជាតិនេះអី ឲ្យបានសុខសប្បាយកុមឲ្យជាតិណាទៅពិបាកដូចជាតិនេះ ។

វណ្ណៈ ៖ បាទ! អញ្ចឹងអ៊ំជឿទេលើបញ្ហាសាសនា?

ម៉ៅ ៖ ជឿណា បានខំរក ។

វណ្ណៈ ៖ បាទ! អញ្ចឹងបើសិនជា អ៊ឹសម័យ៣ឆ្នាំ សម័យ ប៉ុល ពត ណា អ៊ំដែលបានគោរពសាសនាទេ?

ម៉ៅ ៖ អត់ ។

វណ្ណៈ ៖ អត់ទេ អត់មានទេ?

ម៉ៅ ៖ អត់មានលោកមានអី ម៉េចដូចសម័យឥឡូវ ។

វណ្ណៈ ៖ ចុះឥឡូវមានអ៊ី?

ម៉ៅ ៖ ឥឡូវមាន ។

វណ្ណៈ ៖ នៅអន្លង់វែងហ្នឹង ស្រុកដូចថាវត្តអារាមអីច្រើនទេកាលហ្នឹង ឥឡូវណាមានវត្តច្រើនទេសព្វថ្ងៃ?

ម៉ៅ ៖ ទេ ឥឡូវនេះក្នុង១ស្រុកអន្លង់វែងនេះ១២វត្តហើយមើលទៅ ។

វណ្ណៈ ៖ ច្រើនណាស់?

ម៉ៅ ៖ ចា៎ ១២វត្ត ។ ១២ ឬ១១ទេ បើមិន១១ ១២ក្នុង១ស្រុកនេះ ។

វណ្ណៈ ៖ បាទ! អ៊ឺ អ៊ំដូចថាជំនាន់មុនណា ជំនាន់ពីដើមដែរចង់និយាយថាទម្លាមទម្លាប់ប្រពៃណីសាសនាហ្នឹងអ៊ំនិយាយមិញហើយ ចង់និយាយថាទម្លាមទម្លាប់ពីដើមមកប្រពៃណីពីដើមមកអ៊ំគិតថាល្អដែរទេអ៊ំ ជំនាន់សីហនុ ជំនាន់អ៊ុនគាត់?

ម៉ៅ : ទេ មានអីដូចជំនាន់យើងមកឥឡូវដែរណា ជំនាន់មកពីមុន ដល់មកពីជំនាន់ ប៉ុល ពត នេះបានអត់មានលោកមានអី មានវត្តអីបានធ្វើបុណ្យធ្វើទាន ។

វណ្ណៈ : ប្រពៃណីធ្វើបុណ្យធ្វើទៀនអត់មានទេ?

ម៉ៅ : ចា៎! អត់មាន ។

វណ្ណៈ : ចុះប្រពៃណីស្លៀកពាក់ពីជំនាន់ខ្មែរក្រហមបានត្រឹមត្រូវទេ?

ម៉ៅ : អត់ ។

វណ្ណៈ : អត់ទេណ៎ ។ ចុះឥឡូវយើងបានត្រឹមត្រូវ?

ម៉ៅ : ឥឡូវមានអី យើងរកបានអញ្ចឹងទៅចង់ស្លៀកពាក់អីក៏បាន ។

វណ្ណៈ : ចុះចំពោះជីវភាពវិញ ជីវភាពអឹកាលពីសម័យ លន់ នល់ ជំនាន់សម្តេចសីហនុ កាលហ្នឹងគ្រួសារ ឪពុកម្តាយអឹមានជីវភាពក្រលំបាក ឬក៏មធ្យមអឹកាលហ្នឹង?

ម៉ៅ : ឪពុកម្តាយខ្ញុំ បងប្អូនច្រើនអត់ដែរហ្នឹងណា ។

វណ្ណៈ : ក្រដែរ?

ម៉ៅ : អត់បានគ្រប់គ្រាន់ផង ។

វណ្ណៈ : បាទ! ចុះជំនាន់ខ្មែរក្រហមពាឆ្នាំ អឹហូបគ្រប់គ្រាន់ទេ?

ម៉ៅ : អត់ៗទេ ។

វណ្ណៈ : អត់ដែរ? ចុះសម័យឥឡូវ?

ម៉ៅ : សម័យឥឡូវធ្វើស៊ីខ្លួនឯង ចង់ស៊ីប៉ុន្មានក៏បាន ។

វណ្ណៈ : អញ្ចឹង ។ ឥឡូវហូបចុកគ្រប់គ្រាន់អឹ?

ម៉ៅ : វាមិនគ្រប់ប៉ុណ្ណា ប៉ុន្តែបានជុំគ្រាន់តែយើងបានធ្វើបានអីកើតខ្លួនឯង ។

វណ្ណៈ : បាទ! អឹគិតថាអញ្ចេះ គិតថាជំនាន់ៗខ្មែរក្រហមធ្វើឲ្យជីវភាពអឹប៉ះពាល់មកដល់សព្វថ្ងៃហ្នឹងទេ ជំនាន់ហ្នឹងណា ។ អឹគិតថាបើកុំមានសង្គ្រាម កុំមានជំនាន់ខ្មែរក្រហម តើជីវភាពអឹអាចធូរធារជាងហ្នឹង ឬក៏ម៉េច?

ម៉ៅ : បានអីធូរធារបើយើងអត់បានធ្វើអីផងហ្នឹង មិនមែនដូចសម័យឥឡូវយើងចង់ទៅណាក៏បាន កាលលើកមុនយើងទៅណាវាមិនរួច ។

វណ្ណៈ : បាទ! ប៉ុន្តែអឹគិតថាដោយសារតែមានសង្គ្រាម ដោយសារតែមានរបបខ្មែរក្រហមពាឆ្នាំហ្នឹងបានធ្វើឲ្យបែកបាក់បងប្អូន ឬក៏ជីវភាពអឹខ្វះខាតខ្សោយដោយសារបញ្ហាហ្នឹងអត់?

ម៉ៅ : ហ្នឹងហើយ ដោយសារអីដោយសារតែយើងអត់បានធ្វើអី ហើយវាសង្គ្រាមផងអីផង យើងមានបានហូបអីគ្រប់គ្រាន់ ។

វណ្ណៈ : បាទ! ចុះអ៊ឹចំពោះគ្រួសារអ៊ឹសព្វថ្ងៃ ដូចថាទំនាក់ទំនងក្នុងគ្រួសារហ្នឹងម៉េចដែរអ៊ឹ រាល់ថ្ងៃគ្រួសារអ៊ឹ កូនចៅអីហ្នឹងទំនាក់ទំនងល្អប៉ុណ្ណាដែរអ៊ឹ?

ម៉ៅ : មានអីធម្មតា ។

វណ្ណៈ : នៅក្នុងគ្រួសារអ៊ឹអត់ដែលប្រើអំពើហិង្សាវ៉ៃតប់អី អត់មាន?

ម៉ៅ : អត់មាន ។

វណ្ណៈ : បាទ! ចុះជំនាន់ខ្មែរក្រហម អ៊ឹបានទាក់ទងបងប្អូនដូចថាអីបានល្អទេ ជំនាន់ខ្មែរក្រហម៣ឆ្នាំ?

ម៉ៅ : ហើយយើងបានអីទាក់ទង បើយើងអត់មានឡានជិះមានអីទៅណាមកណើ បើយើងនៅកន្លែងណានៅតែកន្លែងហ្នឹង អត់ដែលបាន ។

វណ្ណៈ : អត់មានទំនាក់ទំនងគ្នាទេ?

ម៉ៅ : បានទាក់ទងអីគ្នាផង បងប្អូនម៉ែឪផងហ្នឹង យើងនៅទីណានៅទីហ្នឹងហើយ ដែលមានអីទៅណាសេរី មានសិទ្ធសេរីភាពដូចរាល់ថ្ងៃនេះអត់ ។

វណ្ណៈ : បាទ! ចុះអ៊ឹដូចថាជំនាន់ពីដើមវិញ យើងបងប្អូនយើងម៉េចដែរ បងប្អូនអ៊ឹបង្កើតណា ជំនាន់លន់នល់ ជំនាន់ស្ដេចសីហនុអី ទំនាក់ទំនងបងប្អូនរាប់អានគ្នាម៉េចដែរអ៊ឹកាលហ្នឹង?

ម៉ៅ : កាលហ្នឹងមានអី អត់អីទេ ។

វណ្ណៈ : ជំនាន់ហ្នឹងអត់អីទេ ។ ចុះចំពោះអ្នកជិតខាងវិញ សព្វថ្ងៃណាតើយើងមានទំនាក់ទំនងល្អយ៉ាងម៉េចដែររាល់ថ្ងៃ?

ម៉ៅ : ទំនាក់ទំនងល្អ ណាទៅមើលចិត្តគេឃើញ ។

វណ្ណៈ : អត់ទេអ៊ឹ មានន័យថាជិតខាងអ៊ឹណា អត់ដែលមានទំនាស់ទាស់ទែងគ្នាអីទេ រាប់អានគ្នាធម្មតាទេ?

ម៉ៅ : ទេ ខ្ញុំដូចគ្មានបញ្ហាអីតែក្រែងលោអ្នកជិតខាង មិនដឹងម៉េច ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ចា៎! យើងមើលចិត្តគេមិនឃើញ ។

វណ្ណៈ : តែនៅស្រលាញ់រាប់អានគ្នា មានរបស់របរអីអាចរាប់អានគ្នាហុចគ្នាទៅវិញទៅមកអីបានទេរាល់ថ្ងៃហ្នឹង?

ម៉ៅ : បានតើ ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ចា៎! គេហុចខ្ញុំ ខ្ញុំហុចគេអញ្ចឹងទៅ ។

វណ្ណៈ : បាទ! អញ្ចឹងអី ជំនាន់ខ្មែរក្រហមយើងទំនាក់ទំនងសាច់ញាតិអីអត់បានទេ?

ម៉ៅ : អត់បានទេ បើយើងនៅកន្លែងណានៅតែកន្លែងហ្នឹងទៅ ហុចឯណាបានអត់ទេ ។

វណ្ណៈ : បាទ!

ម៉ៅ : យើងនៅកងណានៅកងហ្នឹង យើងនៅទីណានៅទីហ្នឹង គេមានឲ្យយើងទៅណាទៅណីចុះឡើង ពីកងមួយទៅកងមួយ នៅនេះយើងចង់ទៅណាក៏បាន យើងមានសិទ្ធសេរីភាពរាល់ថ្ងៃ គ្រាន់ថាពីមុនយើងអត់មានសិទ្ធសេរីភាពអី មានដើរទៅណាបាន ។

វណ្ណៈ : បាទ! អញ្ចឹងដូចថារាល់ថ្ងៃ កូនចៅអ៊ឹរៀនសូត្រអីដល់កម្រិតណាដែរ កូនចៅអ៊ឹបានរៀនដែរ?

ម៉ៅ : បានរៀនតិច ។

វណ្ណៈ : បានរៀនតិចតួចទេ?

ម៉ៅ : ចា៎!

វណ្ណៈ : ម៉េចអញ្ចឹងអ៊ឹ អត់បានឲ្យកូនចៅអ៊ឹបានរៀនសូត្រ?

ម៉ៅ : ចុះបើកាលហ្នឹងវាអត់មានសាលារៀន ។

វណ្ណៈ : កាលសង្គ្រាម?

ម៉ៅ : ចា៎!

វណ្ណៈ : ដល់ពេលផុតសង្គ្រាមទៅកូនធំៗអស់ទៅ?

ម៉ៅ : បើមិនទាន់ផុតសង្គ្រាមផងកូនការអស់ ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : អត់មានបានរៀនទេ រៀនបានតិចតួច ។

វណ្ណៈ : អញ្ចឹងអ៊ឹគិតថា ការរៀនសូត្រមានសារៈសំខាន់អត់អ៊ឹ?

ម៉ៅ : រៀនសូត្រ អាហ្នឹងក៏យើងរួមចំណែកមួយ បើយើងចេះដឹងទៅយើងធ្វើអ្វីៗមួយក៏បាន បើយើងអត់ចេះអញ្ចឹងធ្វើអីកើត ដូចខ្ញុំទៅធ្វើអីកើត ធ្វើស្រែហ្នឹង ។

វណ្ណៈ : បាទ! ចុះអ៊ឹដូចថាបើគិតមកដល់ឥឡូវហ្នឹងណា តើអ៊ឹគិតថាគួរតែរក្សាទុកចង្រ្កងអីស្នាដៃតាម៉ុកហ្នឹងទុកឲ្យក្មេងជំនាន់ក្រោយអ៊ឹគិតថាមានសារៈសំខាន់ទេ?

ម៉ៅ : ចុះបើមានអីនឹងគិតបើខ្ញុំកូនអត់សូវចេះផង ។

វណ្ណៈ : ចង់និយាយថា ដូចថាទំនប់ថ្មី សាលារៀនហ្នឹងណាអ៊ី តា ម៉ុក កសាងហ្នឹង អាចំនុចអស់ហ្នឹង គួរតែយើងរក្សាទុកជាប្រវត្តិសាស្ត្រដែរអ៊ឹ ឬក៏យ៉ាងម៉េច?

ម៉ៅ ៖ ចុះសព្វថ្ងៃមានគេ អត់មានរំលាយឯណាទុកទាំងអស់ ចា៎! នៅទាំងអស់ អាទំនប់នេះមួយណា ទំនប់គាត់ទប់នេះមួយ អាទប់ផ្លូវយើងទៅព្រលានហ្នឹង អាកន្លែងដាច់ហ្នឹងណា នៅកន្លែងដាច់ដដែលមានណាគេកសាងអីទៀត បើនៅរបស់គាត់នៅប៉ុណ្ណឹងដដែល អត់មានណាគេជួសជុលអីបន្ថែមទៀតទេ ដល់សព្វថ្ងៃ នៅតែប៉ុណ្ណឹង ។

វណ្ណៈ ៖ បាទ!

ម៉ៅ ៖ ប៉ុនដល់ទំនប់ថ្មីទំនប់អីនោះគេអត់មានបាក់បែកអីទេ នៅស្អាត ហើយមន្ទីរពេទ្យ សាលារៀនអីហ្នឹងគេ មិនធ្វើអីតទៅទៀតឃើញនៅតែប៉ុណ្ណឹងដដែល ។

វណ្ណៈ ៖ ចុះអ៊ីដូចថាចំណុចទាំងអស់ហ្នឹង ដូចថាយើងគួរតែរក្សាទុកជាប្រវត្តិសាស្ត្រដែរ?

ម៉ៅ ៖ ចុះហ្នឹងគេទុកតើ យើងមានរក្សាធ្វើអីផង បើថាមន្ទីរពេទ្យ សាលារៀនទៅ យើងទុកមានត្រូវរំលាយត្រូវអីទៀត គេខំកសាងឡើង ។

វណ្ណៈ ៖ អ៊ី មកមើលមើល៎ស្រុកអន្លង់វែងយើងសព្វថ្ងៃមានការរីចម្រើនដែរ ឬក៏យ៉ាងម៉េចដែរ បើតាមទស្សនៈរបស់អ៊ីណា?

ម៉ៅ ៖ រីកដូចគេតែអ្នកមានៗណា យើងអ្នកក្រក៏គ្មានរីកទៅណា ។

វណ្ណៈ ៖ ប៉ុន្តែអ៊ីគិតថា កាលជំនាន់តាម៉ុកហើយមកដល់ឥឡូវនេះ អ៊ីគិតថាប្រជាជនមានជីវភាព ធូរធារអី មានលក្ខណៈរស់នៅបានសុខសប្បាយ បានធូរធារយ៉ាងម៉េចដែរ ចង់សួរអញ្ចឹងណាអ៊ីណា?

ម៉ៅ ៖ អូ! មើលមានតើវា មិនដូចជំនាន់នោះពេកដូចថាវាធូរធារធ្វើផ្ទះធ្វើសម្បែងអញ្ចឹងទៅ បើជំនាន់តាគេនៅតែធ្វើតូចៗដដែល បើថាគេរីកចម្រើន អ្នកណាគេដូចថារកបានអញ្ចឹងទៅគេធ្វើទៅធម្មតាគេរីកចម្រើនហើយ ។

វណ្ណៈ ៖ អញ្ចឹង កាលជំនាន់តាម៉ុកដូចថាមានផ្ទះថ្ម មានផ្ទះឈើធំៗដែរអ៊ី?

ម៉ៅ ៖ អត់មាន ។

វណ្ណៈ ៖ អត់មានទេអ៊ី?

ម៉ៅ ៖ ចា៎! មានតែសាលារៀនមួយ ហើយមន្ទីរពេទ្យទៅ គាត់កសាងប៉ុណ្ណឹង ។

វណ្ណៈ ៖ ចុះកាលហ្នឹងអ៊ីមក អ៊ីជាចាស់ៗជំនាន់មុនអញ្ចឹង កាលហ្នឹងព្រៃឈើអីយ៉ាងម៉េចដែរ អ៊ីទាន់ដល់ជំនាន់ក្រោយៗនេះលែងដឹងថាមានព្រៃឈើធំៗហើយកាលហ្នឹង កាលជំនាន់អ៊ីមកនៅហ្នឹង ព្រៃឈើយ៉ាងម៉េចដែរអ៊ី សត្វព្រៃអីយ៉ាងម៉េចដែរ?

ម៉ៅ ៖ មានអី ឥឡូវអត់មានផង កាលមុនសម្បូរមានអត់អី សត្វព្រៃអីសម្បូរ ។

វណ្ណៈ ៖ ឥឡូវព្រៃអស់ហើយណ៎អ៊ី?

ម៉ៅ ៖ ឥឡូវអស់រលីងហើយ (០០:៥៤:៤០)គ្មានអីបន្តិចទេឥឡូវ តែបើជំនាន់គា នៅនេះឯង វាមិនបាត់បង់អី ដល់មកឥឡូវអស់រលីងហើយ ។

វណ្ណៈ ៖ ចុះគេថាជំនាន់គាម៉ុកកាប់ឈើលក់ឲ្យថៃដែរនោះអី?

ម៉ៅ ៖ មាន តែគាត់កាប់តែអាធំៗ ដល់មកឥឡូវរលីងអស់ហើយគ្មានសល់ទេ ។

វណ្ណៈ ៖ ម៉េចបានគេកាប់រលីងអញ្ចឹង?

ម៉ៅ ៖ មិនដឹង ។

វណ្ណៈ ៖ គេកាប់យកទៅធ្វើស្រែ ឬក៏យ៉ាងម៉េច? ប្រជាជនយើងកាប់ ឬក៏ពីណាកាប់?

ម៉ៅ ៖ ប្រជាជនខ្លះ ប្រជាជនគ្នាកាប់គាស់បានបន្តិចបន្តួចហ្នឹង មិនដែលនឹកឃើញដាំអីទេ ដាំតែស្រូវហូប ដល់អ្នកថៅកែគេធំៗអញ្ចឹង គេក៏ធ្វើគេ ដាំកៅស៊ូដាំអីអញ្ចឹងទៅ ដល់ប្រជាជនគេនៅនេះក្រនេះមានធ្វើអី អត់ គ្រាន់តែដាំស្រូវអីបន្តិចបន្តួចខ្លះបាន១ហត្ថអញ្ចឹង ខ្លះបាន១ហត្ថអញ្ចឹងទៅ ។

វណ្ណៈ ៖ ចុះអ៊ំគិតថានៅអន្លង់វែងអ៊ំគិតថា ក្រុមហ៊ុន រោងចក្រអីគេមកវិនិយោគទុនធ្វើស្រែ ចម្ការមកវិនិយោគទុនធ្វើអីមួយនៅហ្នឹងនៅ?

ម៉ៅ ៖ អត់ ។

វណ្ណៈ ៖ អត់ដែរឃើញទេ?

ម៉ៅ ៖ អត់ដែលឃើញ ។

វណ្ណៈ ៖ ចុះបញ្ហាដីធ្លីអី នៅក្នុងអីស្រុកអន្លង់វែងហ្នឹង តើមានបញ្ហាដែរអត់អី?

ម៉ៅ ៖ មានបញ្ហាដែរហ្នឹងបញ្ហាដូចថារដ្ឋពីមុន យើងធ្វើចម្ការធ្វើស្រែ ដល់មកឥឡូវដូចថាមានក្រុមហ៊ុន គេប្រកាសដែរហ្នឹងប៉ុនខ្ញុំមិនដែលចាំអាក្រុមហ៊ុនគេហ្នឹង ក្រុមហ៊ុនគេយកដីឥឡូវហ្នឹងគេចែកឲ្យក្នុង១គ្រួសារ ឲ្យតែ១ហត្ថកន្លះទេ ដូចថាគ្នាធ្លាប់មាន៥ហត្ថ ៦ហត្ថ អញ្ចឹងទៅដល់ឥឡូវចំអាដីក្រុមហ៊ុនគេហ្នឹង គេឲ្យតែ១គ្រួសារ១ហត្ថកន្លះ ពីមុនកាលមិនទាន់ចុះវាស់ចុះអីថាគេឲ្យ២ហត្ថកន្លះ ដល់មកឥឡូវគេប្រកាសថ្ងៃមុនថាគេឲ្យតែ១ហត្ថកន្លះទេ ។

វណ្ណៈ ៖ ចុះប្រជាជនព្រមយកទេ១ហត្ថកន្លះហ្នឹង?

ម៉ៅ ៖ ប្រជាជនទោះបីគ្នាមិនព្រមក៏ មិនដឹងទៅណាទៀតបើគ្នាអត់ដឹង ។

វណ្ណៈ ៖ ១ហត្ថកន្លះហ្នឹងមានគេទទួលយកនៅ?

ម៉ៅ ៖ ហ្នឹងហើយប្រជុំហ្នឹង គេថាឲ្យទះដៃក៏ទះដៃហ្នឹងគេទៅ គេឲ្យមើលក៏មើលហ្នឹងគេទាំងគេទាំងខ្ញុំចុះមានដឹងថាយ៉ាងម៉េច ហើយឥឡូវហ្នឹងអាខ្លះមកគ្នាមានដីប៉ុណ្ណឹងអាខ្លះគ្នានេះ វាប្រជុំបាក់តែគ្នាឯង អ្នកគ្នាធ្លាប់បាន៥ហត្ថអញ្ចឹងទៅ គ្នាអ្នកកូនច្រើនអញ្ចឹងធ្វើបាន៥ហត្ថ ៤ហត្ថ

អញ្ចឹងទៅ ដល់អាពេលគេចែកបាន១ហត្ថកន្ទះ ៗ គេនឹកកូនអញអីយមិនដឹងអញពីមុនទៅគ្មានស៊ី ដល់មកកូននេះគ្មានស៊ីទៀតម្នាក់ៗតូចចិត្តអញ្ចឹង តូចចិត្តថាដីក្រុមហ៊ុនយកអស់ ខំគាស់ខំកាយ ជួនណាគ្នា៥ហត្ថហ្នឹងធ្វើហើយទាំងអស់ ៗ អត់មានសល់ទេថាធ្វើឡើងវារដួរអញ្ចឹងណា ហើយឥឡូវហ្នឹង ឮថាប្រជុំថ្ងៃមុនហ្នឹងគេប្រកាសថាឲ្យតែ១ហត្ថកន្ទះទេ ហើយគ្នាព្រួយបារម្ភថាស៊ីមិនឆ្អែតអញ្ចឹងណា អាខ្លះគ្នាមានកូន២កូន៣ ៣-៤អញ្ចឹងទៅ ហើយ១ហត្ថកន្ទះ ៗ ចុះកាល៥ហត្ថនៅមានបានដោះដូរអី លក់ដូរខ្លះទៅទិញប៊ីចេង ទិញអំបិលទិញប្រហុក ទិញខោអាវ សម្លៀកបំពាក់ឲ្យកូនអញ្ចឹងទៅណា ហើយដល់មកឥឡូវបានគេចែកឲ្យ១ហត្ថកន្ទះកូនអញច្បាស់ជាងាប់ហើយអញ្ចឹងណា ម្នាក់ៗទន្ទេញតែអញ្ចឹង ៗ

វណ្ណៈ : ឥឡូវបានតែ១ហត្ថកន្ទះទេ?

ម៉ៅ : ចា៎! គេប្រកាសហើយបានតែ១ហត្ថកន្ទះទេ ឲ្យតែ១ហត្ថកន្ទះទេ ៗ

វណ្ណៈ : បាទ! ចុះឥឡូវអ៊ំ បើអញ្ចឹងពាក់ព័ន្ធនឹងច្បាប់ទម្លាប់យើងសព្វថ្ងៃហ្នឹងណា អ៊ំជឿលើច្បាប់យើងរាល់ថ្ងៃហ្នឹងទេ ច្បាប់រដ្ឋាភិបាលយើងរាល់ថ្ងៃចេញមកអីអញ្ចឹងណា ដូចថាមានកូនចៅដល់អ៊ំចេញទៅប្ដឹងផ្ដល់ អីហ្នឹងអ៊ំសង្ឃឹមទៅលើផ្លូវច្បាប់ទេ?

ម៉ៅ : សង្ឃឹមតែមិនដឹងយើងទៅផ្លូវណា បើគ្មានរយៈគ្មានអីបើទៅដល់ណាខ្លាចអញ្ចេះខ្លាចអញ្ចុះគ្មានអត់ដឹងទៅណា អត់ទេនៅស្ងៀមអញ្ចឹងទាំងអស់តែគ្នាទៅ ៗ

វណ្ណៈ : តែអ៊ំគិត ៗ

ម៉ៅ : ឲ្យប៉ុណ្ណាយកប៉ុណ្ណឹងទៅ ៗ

វណ្ណៈ : ចុះអ៊ំគិតថាច្បាប់រាល់ថ្ងៃល្អដែរ ឬក៏មិនល្អទេ?

ម៉ៅ : វាមិនដឹងថាយ៉ាងម៉េចល្អ យ៉ាងម៉េចអាក្រក់ទៀតណាបើមិនចេះហ្នឹងណា វាអត់ដឹង ៗ

វណ្ណៈ : ចុះច្បាប់ជំនាន់ខ្មែរក្រហមល្អទេ ច្បាប់ជំនាន់ហ្នឹង?

ម៉ៅ : វាមិនដឹងថាល្អ ឬមួយអាក្រក់ ប៉ុនបើរឿងដីធ្លីថាយើងធ្វើបានប៉ុន្មានធ្វើទៅស្រេចអ្នកឯង ៗ

វណ្ណៈ : តែឥឡូវៗអ៊ំថាឥឡូវច្បាប់ឥឡូវអ៊ំថាមិនដឹងល្អអាក្រក់អញ្ចឹង ចង់និយាយថាច្បាប់ជំនាន់ខ្មែរក្រហមគ្រប់គ្រង តើច្បាប់ខ្មែរក្រហមតឹងរ៉ឹង ឬក៏យ៉ាងម៉េចដែរ?

ម៉ៅ : កាលនោះថាវាតឹងរ៉ឹងមិនឲ្យដើរទៅនេះទៅនោះ ហើយមិនឲ្យទាក់ទងអីបងប្អូនអានោះថាវាតឹងហើយ?

វណ្ណៈ : តឹងពេក?

ម៉ៅ : ចា៎! នោះវាតឹងពេក ដល់មកឥឡូវនេះ ដល់ពេលនេះវាមិនថាវាថា ប៉ុនដល់ទើបមកពេលនេះថាមានក្រុមហ៊ុនយកដីអញ្ចឹង ដល់ហើយម្នាក់ៗទើបគិតឃើញហើយថា កូនអញហើយ

អញជំនាន់នេះហើយអញឆាប់ងាប់ហើយ ប៉ុនដល់មកជំនាន់អាកូនអញក្រោយច្បាស់ជាធ្វើខ្ញុំគេ១ជីវិតហើយមានអញ្ចឹងឯង ណាមាននិយាយអញ្ចឹងឯង ។

វណ្ណៈ : ចុះអ៊ីអត់សប្បាយចិត្តទេ ពេលក្រុមហ៊ុនមកអញ្ចឹងអ៊ី?

ម៉ៅ : អត់សប្បាយចិត្ត ក៏មិនដឹងរស់នៅណា បើយើងនៅហ្នឹងហើយ ។

វណ្ណៈ : ចុះបើក្រុមហ៊ុនគេមកបង្កើតកៅស៊ូដាំបានច្រើន កូនចៅបានការងារធ្វើអ៊ីសប្បាយចិត្តទេ?

ម៉ៅ : ទេ មានអីអញ្ចឹងបានថាយើងអត់មានសិទ្ធស្អីដូចថា អត់មានសិទ្ធមានដីមានធ្លីអីដាំហ្នឹងគេបានថាធ្វើខ្ញុំក្រុមហ៊ុន១ជីវិតហ្នឹងណា អញ្ចឹងណា ។

វណ្ណៈ : វាទៅអញ្ចឹងវិញ ។

ម៉ៅ : ហើយបើខ្ញុំណា ជំនាន់ខ្ញុំនេះវាផុតហើយ ប៉ុនដល់អាកូនចៅបន្តទៅក្រោយទៀត ។

វណ្ណៈ : បាទ! អញ្ចឹងអ៊ីពាល់ថ្ងៃដូចជា ដូចថាបើសិនជាមានអ្នកជនអន្តោប្រវេសន៍យួនអី មកនៅជិតៗហ្នឹង អ៊ីសប្បាយចិត្តទេ យួន ថៃអីមកនៅហ្នឹង សប្បាយចិត្តទេ?

ម៉ៅ : សប្បាយចិត្តអី បើប្រជាជនគេ ជនជាតិគេៗមានទឹកដីគេ ហើយដល់មកនៅភូមិអញ្ចឹង ។

វណ្ណៈ : អ៊ីអត់សប្បាយចិត្តទេ?

ម៉ៅ : ហ្នឹងហើយ ។

វណ្ណៈ : ចុះបើប្រជាជនខ្មែរយើងមកទិញដីទិញអីមកស្រុកហ្នឹង នៅរស់នៅជាមួយនៅភូមិជុំអ៊ីដែរអ៊ីសប្បាយចិត្តឬក៏មិនសប្បាយចិត្ត?

ម៉ៅ : ទៅមានដីណាលក់បើដីក្រុមហ៊ុនយកអស់ហើយ ។

វណ្ណៈ : អត់ទេ ឧបមាថាអ្នកស្រុកអ្នកភូមិពីក្នុងអី គេមកទិញដីប្រជាជនណា អ៊ីអត់មានដីលក់តែមានមនុស្សកាន់តែច្រើនទៅ អ៊ីសប្បាយចិត្តទេបើសិនជាខ្មែរដូចគ្នា?

ម៉ៅ : ទេ មានអីខ្មែរដូចគ្នា ធ្វើម៉េចបើយើងជនជាតិយើងដូចគ្នានោះ ។

វណ្ណៈ : បាទ! បើជនជាតិគេអត់សប្បាយចិត្តទេ?

ម៉ៅ : អត់សប្បាយចិត្តទេ នោះគេមានទឹកមានដីគេ យើងមានទឹកមានដីយើងហើយដល់គេ ឯងខំគាស់កាយអញ្ចឹងបាន២-៣ហត្ថអញ្ចឹង ដល់ឥឡូវនេះគេបែកឲ្យ១ហត្ថកន្លះ យើងតូចចិត្តត្រង់ថាយើងបានតិចហើយគ្មានបានប្រកបដោយផលអី ។

វណ្ណៈ : បាទ! ចុះអ៊ីឥឡូវចំពោះយើងបញ្ហា នៅប្រទេសថៃនៅប្រទេសអីហ្នឹង យើងអាចចេញចូលបានស្រួលទំនាក់ទំនងបានទេអ៊ី?

ម៉ៅ : មានអី នេះខ្ញុំមិនដែលទៅមកផង ប៉ុនអ្នកឃើញអ្នកគេទៅមកគេទៅមកបានអញ្ចឹង ខ្ញុំមិនដែលទៅមកផង ដូចថាឈើថ្កាត់អីអញ្ចឹងយើង មានអាសន្នអីអញ្ចឹងឃើញគេយកទៅ ។

វណ្ណៈ : ទៅថៃទៅអីដែរ?

ម៉ៅ : ចាំ!

វណ្ណៈ : អញ្ចឹងយើងទំនាក់ទំនងជាមួយប្រទេសថៃអត់អីទេ?

ម៉ៅ : ចាំ!

វណ្ណៈ : បាទ!

ម៉ៅ : បើកាលវៃគ្នា ហ្នឹងបានអត់ ។ ប៉ុនឥឡូវដូចឃើញគេ ឈឺថ្កាត់អីឃើញគេយកទៅបានដែរ ។

វណ្ណៈ : បាទ! ចុះមកដល់ឥឡូវអ៊ីមានចិត្តចង់ទៅស្រុកកំណើតវិញ រស់នៅស្រុកកំណើតវិញទេអ៊ី?

ម៉ៅ : អត់! បើស្រុកកំណើតគេចែកដីចែកធ្លីអស់ហើយ ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ចាំ! បើខ្ញុំទៅក៏ខ្ញុំមិនមានអី ។

វណ្ណៈ : បាទ! ចុះឪពុកម្តាយអ៊ី អ៊ីអញ្ចេះដូចថាឥឡូវបងប្អូនអ៊ីមកនៅនេះប៉ុន្មាននាក់ដែរ?

ម៉ៅ : មានតែខ្ញុំ១ ។

វណ្ណៈ : អញ្ចឹង?

ម៉ៅ : ចាំ!

វណ្ណៈ : អញ្ចឹងពេលចូលឆ្នាំចូលអី អ៊ីទៅលេងស្រុកកំណើតដែរ?

ម៉ៅ : ចូលឆ្នាំ២ឆ្នាំហើយ តាំងពីប្តីខ្ញុំខូចខ្ញុំអត់ដែលបានទៅ កាលមុនខ្ញុំទៅរាល់តែឆ្នាំ ។

វណ្ណៈ : មុនប្តីខូចទៅរាល់ឆ្នាំដែរ?

ម៉ៅ : ចាំ! ដល់ប្តីខ្ញុំខូចអញ្ចឹង ខ្ញុំអត' បានទៅទេ២ឆ្នាំហើយ ។

វណ្ណៈ : ចុះឪពុកម្តាយអ៊ីស្លាប់អស់ហើយ?

ម៉ៅ : ស្លាប់អស់ហើយ ។

វណ្ណៈ : ស្លាប់តាំងពីនាន់ណាទៅ?

ម៉ៅ : ស្លាប់ពេល ឪពុកម្តាយខ្ញុំស្លាប់ជាង១០ឆ្នាំហើយ ។

វណ្ណៈ : ស្លាប់ក្រោយ៧៩នេះទេ?

ម៉ៅ : អឺ មុនខ្ញុំផ្លាច់ខ្លួនមក ។

វណ្ណៈ : អញ្ចឹងអ៊ីអត់បានជួប ឪពុកម្តាយទេ?

ម៉ៅ : អត់ទេ ។

វណ្ណៈ : អ៊ីបែកឪពុកម្តាយតាំងពី៧៥មក?

ម៉ៅ : ចា៎! ៧៥-៧៦ ប៉ុនដល់ពេលនេះទៅបានជួបម្ដាយបាន ៨ខែ។

វណ្ណៈ : ជួបនៅណា?

ម៉ៅ : ទេ ដល់ពេលយើងផ្ដាច់ខ្លួនអញ្ចឹង យើងទៅស្រុក។

វណ្ណៈ : អូ! អញ្ចឹងឪពុកស្លាប់មុន?

ម៉ៅ : ចា៎! ឪពុកស្លាប់មុន។

វណ្ណៈ : ចុះបងប្អូនថាចូលបដិវត្តន៍ ២នាក់ទៀតនោះគាត់ស្លាប់ឬគាត់នៅ?

ម៉ៅ : ស្លាប់អស់ហើយ។

វណ្ណៈ : ម៉េចដឹងថាស្លាប់?

ម៉ៅ : ដឹងថាស្លាប់អា៧៩ហ្នឹង វាអត់ដែលទៅផ្ទះទល់សព្វថ្ងៃ។

វណ្ណៈ : អូ! អញ្ចឹង?

ម៉ៅ : ចា៎!

វណ្ណៈ : អញ្ចឹងអ៊ំមានកូនចៅ កូនប្រសារកើតកូនកើតចៅនៅនេះហើយលែងទៅស្រុកហើយ?

ម៉ៅ : ចា៎! ខ្ញុំទៅស្រុកអី ខ្ញុំអត់មានដីមានធ្លីអី។

វណ្ណៈ : ចុះដូចថាថ្ងៃក្រោយទៅផ្សើរលើទឹកដីអន្លង់វែងហើយជីវិតអីស្លាប់រស់នៅហ្នឹងហើយអញ្ចឹង?

ម៉ៅ : ចា៎!

វណ្ណៈ : ចុះអ៊ំ ដូចរាល់ថ្ងៃនេះអ៊ំប្រកបរបរធ្វើស្រែចម្ការ?

ម៉ៅ : ចា៎!

វណ្ណៈ : ធ្វើដាំដំឡូងដាំអីម៉េចដែរអ៊ំ?

ម៉ៅ : ខ្ញុំអត់ដែលបានដាំដំឡូងទេ មានតែធ្វើស្រែ។

វណ្ណៈ : ធ្វើស្រែ ធ្វើគ្រាន់តែហូបទេអ៊ំ?

ម៉ៅ : ចា៎! ធ្វើបានគ្រាន់ហូប។

វណ្ណៈ : ចុះអ៊ំមានអីបន្ថែមដែលខ្ញុំមិនបានសួរទេ អ៊ំចង់សំណូមពរនិយាយអីទៀតទេអ៊ំ? ចុះអ៊ំខ្ញុំចង់សួរអ៊ំទៀត បើសិនបើខ្ញុំចង់សម្ភាសអ្នកណាដែលគេស្គាល់ប្រវត្តិច្បាស់លាស់ទេ អ៊ំមានដឹងទេ ថាអាចស្គាល់ពីណាទៀតអាចប្រាប់ខ្ញុំថា គេអាចដឹងប្រវត្តិអន្លង់វែងច្បាស់ជាងអ៊ំអី?

ម៉ៅ : ទេ វាមិនដូចគ្នាបើមនុស្សមកអន្លង់វែង មកទាំងអស់គ្នា មករស់នៅៗទាំងអស់គ្នា វាមានដឹងថាអ្នកណាដឹងជាអ្នកណា។

វណ្ណៈ : បាទ! អញ្ចឹងខ្ញុំអរគុណអ៊ំច្រើនណាស់។

ម៉ៅ : ចា៎!

ចប់